ក្រសួងកិច្ចការនារី





# ឥរិយាបថ

## ទំនាក់ទំនង និងឥរិយាបថយេនឌ័រ

## ការប៉ាន់ប្រមាណអំពីយេនឌ័រនៅកម្ពុជា

២០១៤

រូបភាពគំរបមុខ

**ស៊ន សៀម៉ី (១៩ឆ្នាំ)** ជាជើងឯកតែក្វាន់ដូ និងជាម្ចាស់មេដាយមាសស៊ីហ្គេមឆ្នាំ២០១៤ ដែលជាលើកដំបូងសម្រាប់កម្ពុជា

ជំពូកទី ២

# តវិយាបថយេនឌ័រ

## ទំនាក់ទំនង និងឥរិយាបថយេនឌ័រ

### បរិបទគោលនយោបាយ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់កំពូលរបស់រដ្ឋ ដែលបានធានាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (មាត្រា៣៥)។ *ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទត្រូវបំបាត់ចោល។ ការធ្វើអាជីវកម្ម លើកម្លាំងពលកម្មរបស់ស្ត្រី ត្រូវហាមឃាត់។ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង គ្រួសារ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយ ប្រពន្ធមួយ* (មាត្រា៤៥)។

- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ នៅបន្តប្តេជ្ញាធ្វើឱ្យប្រសើរឡើង នូវស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ តាមរយៈការអនុវត្តន៍ការលើកកម្ពស់សមភាពយេនឌ័រ។គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា នៅក្នុងគោលដៅទី៣ មានគោលដៅជាក់លាក់ក្នុងការធ្វើឱ្យចេញជារូបរាងឡើង នូវសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេស ក្នុងវិស័យអប់រំ វិស័យសេដ្ឋកិច្ច និងក្នុងស្ថាប័នសាធារណៈ លើការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្ត។

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ២០១៤-២០១៨ គឺជាផែនការជាក់លាក់របស់ជាតិដែលបានបង្ហាញថាការបញ្ជ្រាបយេនឌ័រជាអន្តរវិស័យ តាមរយៈបញ្ជ្រាបក្នុង



▲ យុទ្ធនាការបុរសពិតកំពុងផ្លាស់ប្តូរឥរិយាបថ និងការប្រព្រឹត្តរបស់បុរស

គោលនយោបាយ កម្មវិធី និងវិស័យនានា និងបន្តបង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យអប់រំ សេដ្ឋកិច្ច ការពារផ្លូវច្បាប់ សុខភាព អេដស៍ និងអាហារូបត្ថម្ភ វិស័យសាធារណៈ និងនយោបាយ។

- ផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ គឺជាផែនការយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ដែលដឹក នាំនិងសម្របសម្រួលក្នុងការអនុវត្តន៍ដោយយន្តការជាតិក្នុងការបញ្ជ្រាបយេនឌ័រ ដូចជាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួងកិច្ចការនារី និងក្រុមការងារយេនឌ័ររបស់ក្រសួង ស្ថាប័ន ។ សេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈ បានកំណត់ឱ្យជ្រើសរើសស្ត្រីពី២០ទៅ៥០% ឱ្យចូលបំរើការក្នុងក្រសួង ស្ថាប័នសាធារណៈ ។ សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ឱ្យមានការជ្រើសតាំងថ្នាក់ដឹកនាំភូមិជាស្ត្រី និងតែងតាំងអភិបាលរងជាស្ត្រី នៅទូទាំងប្រទេស ។

## របកគំហើញ៖ លទ្ធផល និងបញ្ហាប្រឈម

ស្ត្រីកម្ពុជាកាន់តែបានទទួលសេរីភាពនិងប្រើប្រាស់សិទ្ធិរបស់ខ្លួនយ៉ាងទូលំទូលាយ តាមរយៈការកើនឡើងនូវឱកាស និងការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ទូលំទូលាយរបស់ប្រទេស ទោះជាយ៉ាងណាក៏ដោយ ស្ត្រីត្រូវបានគេរំពឹងថាត្រូវគោរព តាមបទដ្ឋានសង្គមនិងជំនឿ ដែលអនុញ្ញាតឱ្យបុរសទទួលបាន«បុព្វសិទ្ធិយេនឌ័រ»របស់ខ្លួន ខណៈដែលស្ត្រីនៅពុំសូវបាន ឱ្យតម្លៃលើសមត្ថភាព និងសក្តានុពលផ្ទាល់ខ្លួន។ បទដ្ឋានសង្គមដែលមិនអាចមើលឃើញ នៅតែបន្តជំរុញឱ្យស្ត្រីធ្វើការនៅក្នុងផ្ទះ និងមើលថែទាំកូនចៅ ដែលក្នុងពេលជាមួយគ្នានោះ ស្ថានភាពសេដ្ឋកិច្ចគ្រួសារបានដាក់សម្ពាធលើ ស្ត្រីឱ្យចូលរួមក្នុងការងាររកប្រាក់ចំណូលផង ដែរ។ ឥទ្ធិពលយេនឌ័រមិនទាន់បានពិនិត្យឱ្យបានម៉ត់ចត់ និងឆ្លុះបញ្ចាំងនៅ ក្នុងការរៀបចំ គោលនយោបាយជាតិ ហើយការយកចិត្តទុក ដាក់នៅមានកម្រិត ដើម្បីដោះស្រាយនិង ផ្លាស់ប្តូរផ្នត់គំនិតសង្គមជាអវិជ្ជមាន ដែលដាក់សម្ពាធលើសេរីភាពរបស់ស្ត្រី។

តាមរយៈការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ បច្ចុប្បន្ន ការចូលរួមរបស់ស្ត្រី និងសមភាពយេនឌ័រមានភាពប្រសើរឡើងស្ទើរគ្រប់វិស័យ ដូចជា ការកើនឡើងនៃចំនួនស្ត្រីក្នុងវិស័យសេដ្ឋកិច្ច វិស័យអប់រំ និងការទទួលបានសេវាអប់រំ ការទទួលបានសេវាសុខភាព ការកើនឡើងចំនួនស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេច និង ការយល់ដឹងអំពីការទប់ស្កាត់ អំពើហិង្សាលើស្ត្រីជាដើម។

ស្របពេលនឹងវឌ្ឍនភាពទាំងនេះ ផ្នត់គំនិត និងឥរិយាបថយេនឌ័រនៅតែមាន ការប្រឈម និងបន្តរាំងដល់ការចូលរួមរបស់ស្ត្រីនៅក្នុងគ្រប់វិស័យ ក៏ដូចជានៅទូទាំង ប្រទេសក្នុងការធ្វើឱ្យស្ត្រីទទួលបានសិទ្ធិ និងឱកាសស្មើគ្នា ដូចមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ។

### ការចូលរួមក្នុងផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីមានការរីកចម្រើនច្រើន ប៉ុន្តែផ្នត់គំនិតសង្គម រារាំងដល់ស្ត្រីក្នុងការពង្រីកឱកាសរបស់ពួកគេ

វិសមភាពយេនឌ័រនៅកម្ពុជាដែលបន្តកើតមាន ត្រូវបានវាស់វែងក្នុងសន្ទស្សន៍ វិសមភាពយេនឌ័រ (Gender Inequality Index-GII) ដែលផ្តោតលើការខាតបង់ ការរីកចម្រើន ដោយសារតែវិសមភាពយេនឌ័រក្នុងផ្នែកចំនួនបី រួមមាន សុខភាពបន្តពូជ ការផ្តល់ភាពអង់អាចដល់ស្ត្រី និងការចូលរួមក្នុងទីផ្សារការងារ ដោយកម្ពុជាជាប់ចំណាត់

ថ្នាក់លេខ៩៦ ក្នុងចំណោមប្រទេសចំនួន១៤៨ (ឆ្នាំ២០១២) [1]។ ក្នុងសន្ទស្សន៍គម្លាតយេនឌ័រសកល ដែលកំណត់ចំណុចដៅគម្លាតយេនឌ័រថ្នាក់ជាតិលើលក្ខណៈវិនិច្ឆ័យផ្នែកសេដ្ឋកិច្ច នយោបាយ ការអប់រំនិងលក្ខ័ណ្ឌសុខភាព និងកម្ពុជាជាប់ចំណាត់ថ្នាក់លេខ១០៨ ក្នុងចំណោម១៤២ប្រទេស(ឆ្នាំ២០១៤)[2] ។ ផ្នត់គំនិតសង្គម ដែលចាក់ឫសយ៉ាងជ្រៅក្នុងសង្គមកម្ពុជា បានរាំងស្ត្រីមិនឱ្យប្រើប្រាស់សមត្ថភាពរបស់ខ្លួនក្នុងរាល់ទិដ្ឋភាពនៃជីវិតរស់នៅរបស់ពួកគេ។

ទោះបីជាការចូលរួមរបស់ស្ត្រីមានកម្រិតខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច (ប្រមាណពី៧៦% ទៅ ៨០% ចន្លោះពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២សម្រាប់ស្ត្រីដែលមានអាយុ១៥-៦៤ឆ្នាំ) ក៏ដោយ ក៏ស្ត្រីទទួលបានអត្ថប្រយោជន៍ពីការចូលរួមនៅមានកម្រិត បើធៀបជាមួយបុរស។ ស្ត្រីដែលមានការងារធ្វើប្រមាណ៧០% ធៀបនឹងបុរសមានការងារធ្វើប្រមាណ ៥៩% នៅតែជាអ្នក «បង្កើតការងារធ្វើដោយខ្លួនឯង»[3]។ ជាមធ្យម ក្នុងចំណោមនិយោជិតដែលទទួលបានប្រាក់ឈ្នួល ស្ត្រីរកប្រាក់ចំណូលបាន៨១%នៃប្រាក់ចំណូលរបស់បុរស[4]។ ដោយសារតែផ្នត់សង្គមដែលកំណត់ពី «ការងារសមស្របសម្រាប់ស្ត្រី» ដូចជាអាជីវករតាមទីផ្សារ ដងផ្លូវ ឬអាជីវកម្មគ្រួសារខ្នាតតូច និងការងារមិនមានជំនាញ រួមមានកម្មកររោងចក្រកាត់ដេរ និងអ្នកបម្រើតាមផ្ទះ[5] ការបែងចែកការងារនៅមានលក្ខណៈធំធេង ហើយស្ត្រីនៅតែបន្តប្រមូលផ្តុំក្នុងការងារដែលមានជំនាញតិចតួច[6] ។

ផ្នត់គំនិតសង្គមបានកម្រិតសមត្ថភាព និងឱកាសរបស់ស្ត្រីក្នុងការចូលរួមការងារដែលមានជំនាញច្រើន ឬការងារក្នុងវិស័យសាធារណៈ។ ការចូលរួមរបស់ស្ត្រីក្នុងសមាគមអាជីវកម្មដែលគ្រប់គ្រងដោយបុរសនៅមានកម្រិត និងក្នុងបណ្តាញព័ត៌មានក្រៅផ្លូវការដែលអាចត្រូវបានចែករំលែកសម្រាប់ឱកាស និងការពង្រីកអាជីវកម្ម។

ស្ត្រី និងក្មេងស្រីភាគច្រើនត្រូវសង្គមតម្រូវឱ្យបំពេញការងារសំខាន់ៗភាគច្រើន ប៉ុន្តែ

1 UNDP, Gender Inequality Index, http://hdr.undp.org/en/content/gender-inequality-index-gii

2 World Economic Forum, Global Gender Gap Index 2013, http://www.weforum.org/issues/global-gender-gap

3 ក្នុងការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០១០ អ្នកដែលបានធ្វើការក្នុងរយៈពេល ៧ ថ្ងៃចុងក្រោយដែលចូលរួមចំណែកដល់គ្រួសាររបស់ខ្លួន ពោលគឺការគ្រប់គ្រងសហគ្រាសរបស់ខ្លួន (ដូចជា កសិករដែលបង្កបង្កើនផលលើដីរបស់ខ្លួន )សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០០៨ «សំឡេងសហគ្រិនស្ត្រីកម្ពុជា» រាជធានីភ្នំពេញ

4 សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ឆ្នាំ២០០៨ «សំឡេងសហគ្រិនស្ត្រីកម្ពុជា» រាជធានីភ្នំពេញ

5 Nakagawa ឆ្នាំ២០០៦

6 Srurn,R , 2013, *“Gender and Human Capital Development, Key challenges”*, USAID, Phnom Penh

នៅក្នុងការងារផ្ទះ និងមើលថែទាំដែលមិនទទួលបានប្រាក់កម្រៃនៅក្នុងគ្រួសារនិងសហគមន៍។ ការនេះបានបង្កជាឧបសគ្គដែលមើលមិនឃើញសម្រាប់ក្មេងស្រី និងរារាំងស្ត្រីមិនឱ្យទទួលបានកម្រិតសិក្សាខ្ពស់ដែលអាចធ្វើឱ្យស្ត្រីទទួលបានការងារមានប្រាក់កម្រៃខ្ពស់ និងកម្រិតជម្រើសជីវិត និងស្វ័យភាពផ្នែកសេដ្ឋកិច្ចក្នុងវដ្តជីវិតរបស់ពួកគេ។

ការកើនឡើងនូវចំនួនស្ត្រីវ័យក្មេងធ្វើទេសន្តប្រវេសន៍ទៅទីក្រុង ដើម្បីស្វែងរកការងារធ្វើគឺដោយសារតែផ្នត់គំនិតសង្គមដែលរំពឹងថា ស្ត្រីត្រូវជួយផ្គត់ផ្គង់ក្រុមគ្រួសារ។ ស្ត្រីទាំងនោះភាគច្រើនកំពុងតែរស់នៅក្នុងស្ថានភាពមួយដែលពុំសូវមានផាសុខភាពនិងសុវត្ថិភាព ដោយសារពួកគាត់ត្រូវសន្សំប្រាក់ផ្ញើទៅឱ្យគ្រួសារដែលរស់នៅតំបន់ជនបទ ដោយជាទូទៅពុំសូវបានគិតគូរពីសុខភាពនិងសុខុមាលភាពរបស់ខ្លួន។ ដោយមិនមានការគាំទ្រពីគ្រួសារនិងមិត្តភក្តិរបស់ខ្លួន ស្ត្រីគិតថាខ្លួនគាត់ទទួលរងភាពងាយរងគ្រោះដោយអំពើហិង្សានិងការកេងប្រវ័ញ្ច។ ការស្រាវជ្រាវថ្មី បានគូសបញ្ជាក់ថា អំពើហិង្សាលើស្ត្រីនៅតំបន់ទីក្រុង គឺមានទំហំទ្វេដងច្រើនជាងអំពើហិង្សាលើស្ត្រីនៅតំបន់ជនបទ[7]។

ស្ត្រីមានលទ្ធភាពតិចតួចជាងបុរស ក្នុងការទទួលបានធនធាន ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន ដោយសារតែផ្នត់គំនិតសង្គម ដែលធ្វើឱ្យស្ត្រីមានអំណាចតិចជាងបុរសក្នុងដំណើរការធ្វើសេចក្តីសម្រេច។ ស្ត្រីមិនសូវទទួលបានព័ត៌មាន ដូចជាបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល (ការចុះបញ្ជីឯកសារពាណិជ្ជកម្មសំខាន់ៗ។ល។) ហើយស្ត្រីក៏ប្រឈមនឹងឧបសគ្គផ្នែកវប្បធម៌ដែលផ្អែកលើផ្នត់គំនិតនិង អាកប្បកិរិយា រួមមានបញ្ហាប្រឈមជុំវិញតុល្យភាពរវាងការងារ និងជីវិត[8]។

ទោះបីជាស្ត្រីគ្រប់គ្រងមុខរបរប្រមាណជាង៦៥%ក៏ដោយ ក៏ប៉ុន្តែ ភាគច្រើន អាជីវកម្មទាំងនោះមានទំហំតូចនិងទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្មមានកម្រិត។ នៅកម្ពុជាមានស្ត្រីជាអ្នកគ្រប់គ្រងមុខរបរតូចតាច នៅតាមផ្លូវមានប្រមាណ៧៥,៧% នៃចំនួនមុខរបរតូចតាចសរុប។ ផ្នត់គំនិតដែលយល់ថាស្ត្រីគួរធ្វើតែ ការងារផ្ទះ បានបង្កជារបាំងដល់ស្ត្រីមិនអាចឱ្យពង្រីកអាជីវកម្មរបស់ខ្លួននិងក្នុងវិស័យផ្សេងទៀត។

---

7 Astbury, Jill, and Fareen Walji. 2013, *Triple Jeopardy: Gender-based violence and human rights violations experienced by women with disabilities in Cambodia.* Phnom Penh: AUSAID, 2013.

8 ឧបសគ្គដែលបានកំណត់ក្នុងចំណោមសហគ្រិនស្ត្រីមានដូចជា៖ ទីកន្លែងដែលស្ត្រីអាចឬមិនអាចធ្វើអាជីវកម្មបាន ប្រភេទការងារដែលស្ត្រីអាចធ្វើបាន បុគ្គលដែលស្ត្រីអាចនៅជាមួយឬមិននៅជាមួយ ការគោរពពីភាគីជាបុរស និងការទទួលយករបស់ប្តីនៅពេលទទួលបានជោគជ័យ។ បញ្ហាតុល្យភាពរវាងការងារ និងជីវិត រួមមានភាពចាំបាច់ក្នុងការបំពេញតួនាទីរបស់ខ្លួនបានល្អក្នុងនាមជាម្តាយឬប្រពន្ធ និងបន្ទុកការងារ (Sambath L. ឆ្នាំ២០១២)។



▲ តម្លៃវប្បធម៌មានឥទ្ធិពលទៅលើឥរិយាបថយេនឌ័រ

## ការពង្រីកឱកាសទទួលបានការអប់រំនិងបណ្តុះបណ្តាលសម្រាប់ក្មេងស្រី ដើម្បីធ្វើឱ្យប្រសើរឡើងនូវការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ខ្លួន

កម្ពុជាសម្រេចបាននូវសមភាពយេនឌ័រក្នុងការចុះឈ្មោះចូលរៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ប៉ុន្តែអត្រាបោះបង់ការសិក្សានិងអត្រាមិនបានបញ្ចប់ការសិក្សារបស់ក្មេងស្រីនៅមានកម្រិតខ្ពស់នៅឡើយ ជាពិសេសភាពខុសគ្នារវាងទីក្រុង និងជនបទ។ បន្ទាប់ពីការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ លទ្ធភាពទទួលបានការអប់រំបន្តសម្រាប់ក្មេងស្រីនៅមានកម្រិត ហើយអត្រាបញ្ចប់ការសិក្សាក៏នៅមានកម្រិតដែរ។ បទដ្ឋានសង្គមដែលធ្លាប់ផ្តល់អាទិភាពឱ្យក្មេងប្រុសទទួលបានការអប់រំខ្ពស់ជាងក្មេងស្រីគឺជាឧបសគ្គសម្រាប់ក្មេងស្រី[9]។ គោលគំនិតរបស់ឪពុកម្តាយដែលកំណត់ថាកូន

[9] របាយការណ៍ជាតិលើកទី៤ និងទី៥ ស្ត្រីពីការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

ស្រីត្រូវជួយធ្វើការងារផ្ទះ និងមើលថែទាំប្អូនៗជាឧបសគ្គរាំងដល់សារៈសំខាន់នៃការអប់រំកម្រិតឧត្តមសិក្សារបស់ស្ត្រីនិងក្មេងស្រី[10] ។

បទដ្ឋានសង្គមនៅកម្ពុជាបានធ្វើឱ្យស្ត្រីនិងក្មេងស្រីឆាប់រៀបការនៅវ័យក្មេងជាងបុរស ដែលឧបសគ្គរាំងដល់ការអប់រំសម្រាប់ស្ត្រីផងដែរ។ ការចូលរៀនយឺតរបស់ក្មេងស្រីជាងក្មេងប្រុស និងការបូកបញ្ចូល គ្នានៃការចូលរៀនយឺតនិងឈប់រៀនមុនក្មេងប្រុសបណ្តាលឱ្យរយៈពេលនៃការសិក្សាសម្រាប់ក្មេងស្រីកាន់តែខ្លី។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០១០ ស្ត្រីប្រមាណ ១ ភាគ ៤ ក្នុងប្រទេសកម្ពុជាដែលមានអាយុចាប់ពី២៥ ទៅ៤៩ឆ្នាំបានរៀបការនៅអាយុ១៨ឆ្នាំ។ អាយុរៀបការជាមធ្យមគឺ ២០,៣ឆ្នាំសម្រាប់ស្ត្រីធៀបនឹង ២២,៦ឆ្នាំសម្រាប់បុរស។ ឥរិយាបថនៃការឆាប់រៀបការបានកម្រិតឱកាសរៀនសូត្ររបស់ក្មេងស្រី ខណៈដែលរៀបការរួច បទដ្ឋានសង្គមជាប្រពៃណីបានតម្រូវឱ្យស្ត្រីទទួលបន្ទុកលើការងារផ្ទះ មើលថែទាំកូន និងមនុស្សចាស់ ។

សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០១៥ ត្រូវបានរំពឹងថាមានការកើនឡើងនូវឱកាសការងារច្រើន ជាងនៅទូទាំងប្រទេស ក៏ប៉ុន្តែនៅតែមានក្តីបារម្ភចំពោះគុណភាពនៃការអប់រំបច្ចុប្បន្ននិង ការខ្វះជំនាញ បច្ចេកទេសរបស់ស្ត្រីកម្ពុជា ប្រៀបធៀបទៅនឹងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់។

បរិមាណគ្រូបង្រៀនជាស្ត្រី មានការថយចុះជាអតិបរិមានៅកម្រិតឧត្តមសិក្សាបើធៀបទៅនឹងកម្រិតអប់រំមូលដ្ឋាន។ ទំនោរទស្សនៈ «បុរសសមជាងស្ត្រី» នៅក្នុងការតែងតាំងតាមមុខតំណែងនៅតែជារបាំងសម្រាប់គ្រូបង្រៀនជាស្ត្រីទទួលបានឱកាសអភិវឌ្ឍខ្លួនដើម្បីទទួលយកតំណែងក្នុងតួនាទីមានសិទ្ធិ សម្រេចនៅគ្រប់លំដាប់ឋានានុក្រមការងារនៃវិស័យអប់រំ។

## សុខភាពស្ត្រីមានភាពល្អប្រសើរជាលំដាប់ ប៉ុន្តការគ្រប់គ្រងខ្លួនឯងទាក់ទងនឹងសុខភាពបន្តពូជ និងរឿងរ៉ាវផ្លូវភេទ នៅមានកម្រិត

អត្រាមរណភាពមាតា(MMR) មានការថយចុះច្រើនជាងពាក់កណ្តាល គឺពី៤៧២ ក្នុងចំណោម១០០.០០០ កំណើតរស់ក្នុងឆ្នាំ ២០០៥ រហូតដល់ ២០៦ ក្នុងចំណោម

[10] របាយការណ៍សិក្សាស្រាវជ្រាវស្តីពីបញ្ហាយេនឌ័រថ្មីៗក្នុងចំណោមស្ត្រី ក្មេងស្រី និងយុវវ័យនៅកម្ពុជា ក្រសួងកិច្ចការនារី ឆ្នាំ២០១១

១០០.០០០ កំណើតរស់ក្នុង ឆ្នាំ២០១០[11] ។ ថ្មីៗនេះ ទារកទើបនឹងកើតច្រើនជាងពាក់កណ្ដាល បានសម្រាលនៅមណ្ឌលសុខភាព។ តួលេខនេះកើនឡើងជាងពីរដង គឺពី២២% ក្នុងឆ្នាំ២០០៥ ដល់៥៤% ក្នុងឆ្នាំ២០១០។ ភាគរយនៃការសម្រាលកូនដោយគ្រូពេទ្យជំនាញ ធម្មតាជាឆ្មបដែលទទួលការបណ្ដុះបណ្ដាលពីក្រសួងសុខាភិបាលក៏មានការកើនឡើងជាងពីរដងក្នុងទស្សវត្សរ៍កន្លងមកនេះ។ និន្នាការវិជ្ជមានទាំងនេះរីកចម្រើនឡើងដោយសារតែការពង្រីកមណ្ឌលសុខភាព ជាពិសេសក្នុងតំបន់ជនបទ ការបន្តកម្មវិធីផ្សព្វផ្សាយ និងការអប់រំដោយភ្នាក់ងារសុខភាពភូមិក្នុងតំបន់ជនបទ ស្ដីពីសារៈសំខាន់និងតម្លៃសមស្របក្នុងមណ្ឌលសុខភាព និងការវិនិយោគរបស់ក្រសួងសុខាភិបាលក្នុងការបណ្ដុះបណ្ដាលឆ្មបបន្ថែម។ទោះជាយ៉ាងណាក៏ដោយ ក៏ឥរិយាបថរបស់ស្ត្រីក្នុងការស្វែងរកការព្យាបាលមានកម្រិតទាប ដោយសារតែកត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ច[12] ។

អត្រានៃការយល់ដឹងអំពីមធ្យោបាយពន្យារកំណើតមានការកើនឡើងទ្វេដងពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០១០ ក្នុងចំណោមស្ត្រីដោយក្នុងឆ្នាំ២០១០ មានស្ត្រី ៣១% ប្រើប្រាស់មធ្យោបាយពន្យារកំណើត។ ប្រការនេះបានបង្ហាញពីកំណើននៃការយល់ដឹងរបស់ស្ត្រីពីសិទ្ធិសុខភាពបន្តពូជ សិទ្ធិសុខភាពផ្លូវភេទ និងការលើកកម្ពស់ជំនាញចរចាជាមួយដៃគូរបស់ពួកគេ។ ស្ត្រីនៅតែមានកម្រិតក្នុងការគ្រប់គ្រងខ្លួនឯងទាក់ទងនឹងបញ្ហាផ្លូវភេទ។ បញ្ហានេះនៅតែចាត់ទុកជាប្រធានបទដែលមានការហាមប្រាមដល់ស្ត្រីភាគច្រើនមិនឱ្យមានការនិយាយដោយបើកចំហ[13]។ ផ្អែកតាមផ្នត់គំនិតសង្គម ស្ត្រីមិនត្រូវបានលើកទឹកចិត្តឱ្យនិយាយដោយចំហពីបញ្ហាផ្លូវភេទ និងមិនត្រូវសកម្មក្នុងការរួមភេទឡើយ[14] ។

លទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០ បង្ហាញថាភាគច្រើនស្ត្រីយល់ស្របថា ប្រពន្ធមានសិទ្ធិបដិសេធមិនរួមភេទជាមួយប្ដីខ្លួនក្នុងកាលៈទេសៈមួយចំនួន ហើយស្ត្រីភាគច្រើនជឿជាក់ថាខ្លួនមានសិទ្ធិ ទាំងនេះក្នុងកាលៈទេសៈណាមួយ ដូចជាក្នុងករណីដែលស្ត្រី «មានការនឿយហត់ ឬមិនមានអារម្មណ៍ផ្លូវភេទ»។ ការអង្កេតតាមដានបន្តរបស់ក្រសួងកិច្ចការនារី ឆ្នាំ២០០៩ បានរាយការណ៍ថា អ្នកឆ្លើយតប ១២% គិតថា បុរសមានសិទ្ធិក្នុងការបង្ខំឱ្យប្រពន្ធខ្លួនរួមភេទ[15]។

---

[11] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១០), អគ្គនាយកដ្ឋានសុខភាព ក្រសួងផែនការ, អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

[12] ការវិភាគយេនឌ័រក្នុងវិស័យសុខាភិបាលកម្ពុជា ឆ្នាំ២០១១, Frieson, Dr. Kate Grace

[13] Department of Media Communication (2013) *Let's Talk About Sex,* in DCM, *Taking a Look, Cambodia 2013.* Phnom Penh, Department of Media Communications, RUPP.

[14] Nakagawa, K. (2006) *More than White Cloth? Women's Rights in Cambodia.* Phnom Penh.

[15] អង្កេតតាមដានស្ដីពី អំពើហិង្សាលើស្ត្រី ក្រសួងកិច្ចការនារី ឆ្នាំ២០០៩

ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា បានរកឃើញថា ស្ត្រីនិងបុរសប្រមាណជាងពាក់កណ្តាល ដែលមានអាយុប្រហាក់ប្រហែលគ្នាយល់ស្របថា «បុរសជាអ្នកសម្រេចថា ត្រូវរួមភេទនៅពេលណា»។

សុខភាពអាហារូបត្ថម្ភរបស់ស្ត្រីនៅតែជាបញ្ហាធ្ងន់ធ្ងរដោយស្ត្រី ២១% ដែលមានអាយុពី១៤ ទៅ ៤៩ឆ្នាំ មានស្ថានភាពខ្វះអាហារូបត្ថម្ភក្នុងឆ្នាំ២០០០[16] ។ តួលេខនេះស្ទើរតែមិនមានការប្រែប្រួលក្នុងឆ្នាំ២០១០ (មាន១៩%)[17]។ សង្គមនៅបន្តទទួលស្គាល់ថា ស្ត្រីមានការលះបង់តាំងពីកុមារភាព ក្នុងការធានាថា នៅពេលដែលមានការខ្វះខាតអាហារ ស្ត្រីតែងតែផ្តល់អាហារដែលមានដើម្បីឱ្យសមាជិកក្នុងគ្រួសារអាចបរិភោគបានឆ្អែត ជាពិសេសសម្រាប់ស្ត្រីដែលរៀបការរួច។ ក៏ប៉ុន្តែ មិនមានការសិក្សាលើឥទ្ធិពលយេនឌ័រក្នុងគ្រួសារ និងសមាជិកគ្រួសារដើម្បីបង្កើតគោលនយោបាយឡើយ។

## បទដ្ឋាន និងឥរិយាបថសង្គមអវិជ្ជមានទាក់ទងនឹងរឿងរ៉ាវផ្លូវភេទរបស់ស្ត្រីនៅតែបន្តរួមចំណែកឱ្យមានការឆ្លងមេរោគអេដស៍ខ្ពស់ក្នុងចំណោមស្ត្រី

ភាគរយ នៃស្ត្រីក្នុងចំណោមមនុស្សពេញវ័យដែលមានផ្ទុកមេរោគអេដស៍ទាំងអស់មានការកើនឡើងពី ៣៨% នៅក្នុងឆ្នាំ១៩៩៧ ទៅ ៥៣% នៅក្នុងឆ្នាំ២០១៤។ តួលេខនេះគឺខ្ពស់ជាងតួលេខជាមធ្យមនៅក្នុងតំបន់ដែលមានពី ៣២ទៅ៣៥% និងអាចបណ្តាលមកពីកត្តាជីវសាស្ត្ររបស់ស្ត្រីមានភាពអំណោយផលក្នុងការឆាប់ទទួលបាននូវការឆ្លងនិងដោយសារភាពទន់ខ្សោយរបស់ពួកគេ ព្រមទាំងកង្វះសិទ្ធិអំណាច ក្នុងការចរចាពីសុវត្ថិភាពផ្លូវភេទ។

គោលគំនិតនិងបទដ្ឋានសង្គមបានគូសបញ្ជាក់អំពីសារៈសំខាន់នៃភាពស្មោះត្រង់ក្នុងចំណងអាពាហ៍ពិពាហ៍និងសីលធម៌ទាក់ទងនឹងការរួមភេទក្នុងចំណោមស្ត្រីនិងក្មេងស្រីក៏ដូចជាការរារាំងស្ត្រីមិនឱ្យយល់ដឹងអំពីអ្វីដែលទាក់ទងនឹងការរួមភេទ និងស្ថិតនៅក្រោមការបង្គាប់បញ្ជាជាដើម។ បុរសត្រូវបានគេរកឃើញថា មានចំណង់និងតម្រូវការរួមភេទខ្លាំងជាងស្ត្រីហើយបទពិសោធន៍ក្នុងការរួមភេទត្រូវបានកត់សម្គាល់ថាមានសារៈសំខាន់ក្នុង

[16] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១០), អគ្គនាយកដ្ឋានសុខភាព ក្រសួងផែនការ, អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

[17] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ឆ្នាំ២០១០), អគ្គនាយកដ្ឋានសុខភាព ក្រសួងផែនការ, អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។



▲ ស្ត្រីទទួលបាននូវផលប្រយោជន៍កាន់តែច្រើនឡើងពីសិទ្ធិ និងសេរីភាពរបស់ខ្លួន។

ការកំណត់ភាពជាបុរស។ បទដ្ឋាន និងគោលគំនិតសង្គមទាំងនេះ រួមទាំងស្ថានភាពជាទូទៅរបស់ស្ត្រីដែលមានកម្រិតទាបជាងបុរស គឺជាឧបសគ្គរារាំងដល់លទ្ធភាពរបស់ស្ត្រី ក្នុងការចរចាពីលក្ខខណ្ឌនៃការរួមភេទ រួមទាំងការប្រើប្រាស់ស្រោមអនាម័យផងដែរ។

ការទិញសេវាកម្មផ្លូវភេទ គឺជាបញ្ហាតែមួយដូចគ្នាសម្រាប់បុរស យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១០ បុរសច្រើនជាងម្នាក់ក្នុងចំណោមបុរស១០នាក់ (១១%) អាយុពី ១៥ទៅ ៤៩ឆ្នាំ ទិញសេវាកម្មផ្លូវភេទនៅក្នុងឆ្នាំមុនការអង្កេត ហើយមានបុរស១,៦% ដែលមានទំនាក់ទំនងដៃគូរួមភេទច្រើននៅក្នុងឆ្នាំមុនការអង្កេត។ នៅក្នុងការសិក្សាស្រាវជ្រាវថ្មីៗនេះនៅក្លឹបកម្សាន្តដែលបុរសចូលចិត្តទៅក្នុងតំបន់ទីប្រជុំជន បានរកឃើញថា អត្រាប្រេវ៉ាឡង់មេរោគអេដស៍មាន១,៦% ក្នុងចំណោមអតិថិជនជាបុរសរបស់ស្ត្រីរកស៊ីផ្លូវភេទ។

ជាទូទៅ លទ្ធភាពរបស់ស្ត្រីនៅមានកម្រិតក្នុងការចរចាពីសុវត្ថិភាពក្នុងការរួមភេទ និងការប្រើប្រាស់ស្រោមអនាម័យ នៅក្នុងបរិបទនៃការទិញលក់សេវាផ្លូវភេទ (មកពីភាពភ័យខ្លាចកើតមានអំពើហិង្សា និងការចង់បានប្រាក់) ឬទំនាក់ទំនងសង្សារ និងអាពាហ៍ពិពាហ៍ (មកពីទំនាក់ទំនងរវាងការមិនប្រើប្រាស់ស្រោមអនាម័យជាមួយនឹងភាពស្មោះត្រង់ និងការជឿជាក់)។

ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាបានបង្ហាញថាស្ត្រី៨៥,១% និងបុរស៧២,៥% នៅចន្លោះ អាយុពី១៨ឆ្នាំដល់អាយុ២៤ឆ្នាំ ហើយស្ត្រី៧៧,៩% និងបុរស៦៨,៩% ដែលមាន អាយុពី១៣ឆ្នាំ ដល់ អាយុ១៧ឆ្នាំ យល់ស្របថា «បុរសមានតម្រូវការរួមភេទច្រើនជាងស្ត្រី»។ ក្នុងចំណោម ស្ត្រីនិងបុរសទាំងនោះ អាយុចាប់ពី១៨ឆ្នាំដល់២៤ឆ្នាំ មាន៦៧,៩%ជាស្ត្រី និង៧១,៤%ជាបុរស ដែលជឿជាក់ថា «ស្ត្រីដែលមានស្រោមអនាម័យតាមខ្លួនងាយទទួលការរួមភេទ» ។ ក្នុងចំណោមនោះមានស្ត្រី ៦២ភាគរយ និងបុរស៦៩,២ភាគរយ ដែលមានអាយុចាប់ពី១៣ឆ្នាំ ដល់១៧ឆ្នាំ បានយល់ស្របនឹងការរក ឃើញខាងលើ។

ឥរិយាបថឆ្ពោះទៅរកតួនាទីយេនឌ័រក្នុងការប្រព្រឹត្តផ្លូវភេទ និងអំពើហិង្សាលើដៃគូស្និទ្ធស្នាលត្រូវបានពិភាក្សាផងដែរលើសមាសភាគនៃការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា។ ស្ត្រីនិងបុរសវ័យក្មេងមួយចំនួនមានការទទួលយកមតិយោបល់ខុសៗគ្នាថាស្ត្រីដែលមានស្រោមអនាម័យតាមខ្លួនងាយទទួលយកការរួមភេទភាគច្រើនជាស្ត្រីប្រកបរបរផ្លូវភេទ។ អ្នកចូលរួមវ័យចំណាស់ទាំងពីរភេទបានសំដែងមតិរបស់ខ្លួនថា ស្ត្រីដែលដាក់ស្រោមអនាម័យតាមខ្លួនអាចត្រូវបានប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ពួកគាត់ ដូចនេះសិទ្ធិក្នុងការការពារខ្លួនពីការឆ្លងជំងឺ និងមានផ្ទៃពោះពិតជាមានសារៈសំខាន់ខ្លាំងណាស់។

## អំពើហិង្សាលើស្ត្រីនៅតែរីករាលដាល និងត្រូវបានអត់ឱន ប៉ុន្តែផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ទី២ បានបង្ហាញអំពីឱកាសក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី

ស្ថិតិស្តីពីអំពើហិង្សាលើស្ត្រី ដែលជាសូចនាករច្បាស់លាស់មួយនៃវិសមភាពយេនឌ័របានបង្ហាញពីអត្រាប្រេវ៉ាឡង់ខ្ពស់នៃអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា។ ការអង្កេតរបស់ក្រសួងកិច្ចការនារីឆ្នាំ២០០៩ បានរកឃើញថា ទំនាក់ទំនងវិសមភាពយេនឌ័របានចាក់ឫស

យ៉ាងជ្រៅ ដោយមានការគ្របដណ្តប់និងគ្រប់គ្រងដោយបុរស ដែលជាការបន្តធ្វើឱ្យឥរិយាបថរបស់បុរសនិងស្ត្រីជាច្រើនងាយទទួលយកការប្រើប្រាស់អំពើហិង្សា។

ការអង្កេតតាមដានបន្តរបស់ក្រសួងកិច្ចការនារី ឆ្នាំ២០០៩ អ្នកឆ្លើយតបមួយចំនួនតូចយល់ឃើញថា អំពើហិង្សាជាសកម្មភាពដែលអាចទទួលយកបាន ដែលចំនួនអ្នកឆ្លើយតបនេះតិចជាងកាលពីឆ្នាំ២០០៥។ មានការចង្អុលបង្ហាញមួយចំនួនថា កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការយល់ដឹងពីសិទ្ធិស្ត្រី បានបង្កើនចំណេះដឹងអំពីទម្រង់នៃអំពើហិង្សា ទំនាក់ទំនងយេនឌ័រទៅនឹងច្បាប់។

ការអង្កេតតាមដានបន្តរបស់ក្រសួងកិច្ចការនារី ឆ្នាំ២០០៩ បានរកឃើញផងដែរថា បុរស ៣០% ជឿជាក់ថា ប្រភេទនៃអំពើហិង្សាជាក់លាក់មួយចំនួនដែលគំរាមកំហែងដល់អាយុជីវិត[18] គឺពេលខ្លះអាចទទួលយកបាន។ ការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាក៏បានបង្ហាញផងដែរថា ស្ត្រី១នាក់ក្នុងចំណោម៣នាក់ ដែលមានអាយុពី១៣ ឆ្នាំដល់ ១៧ឆ្នាំ និងស្ត្រីម្នាក់ក្នុងចំណោមស្ត្រី៣នាក់ ដែលមានអាយុពី ១៨ ទៅ ២៤ឆ្នាំយល់ស្របថា ប្តីអាចវាយដំប្រពន្ធរបស់ខ្លួនក្នុងកាលៈទេសៈមួយ ឬច្រើន[19]។ បុរស២នាក់ក្នុងចំណោម៥នាក់ ដែលមានអាយុពី១៣ឆ្នាំ ដល់ ១៧ឆ្នាំ និងច្រើនជាង១នាក់ក្នុងចំណោម៣នាក់ ដែលមានអាយុពី១៨ឆ្នាំ ដល់ ២៤ឆ្នាំយល់ស្របថាប្តីប្រព្រឹត្តអំពើហិង្សាលើរាងកាយម្តងម្កាល។ ស្ត្រី៧នាក់ក្នុងចំណោម១០នាក់ និងបុរស៣/៤ជឿជាក់ថា ស្ត្រីគួរអត់ឱនដល់ការប្រព្រឹត្តអំពើហិង្សាដើម្បីអាចរស់នៅជាមួយគ្នាក្នុងគ្រួសារ។

សំណួរនៅក្នុងការសិក្សាស្រាវជ្រាវស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាថាតើ ស្ត្រីគួរអត់ឱនដល់ការប្រព្រឹត្តអំពើហិង្សាឬទេដើម្បីអាចរស់នៅជាមួយគ្នាក្នុងគ្រួសារនោះ គឺមានចម្លើយខុសគ្នាទៅតាមតំបន់។ ក្រុមស្ត្រីដែលរស់នៅរាជធានីភ្នំពេញបានយល់ស្របដូចគ្នាពីព្រោះវាអាចធ្វើឱ្យមានការលែងលះ និងប៉ះពាល់ដល់អនាគតកូនទៀតផង។ ជាមួយគ្នានោះដែរស្ត្រីនៅក្នុងខេត្តព្រៃវែងបានបដិសេធការរកឃើញខាងលើ។ បុរសវ័យក្មេងភាគច្រើនបានបដិសេធអំពីការរកឃើញនេះ ដោយលើកឡើងថាមិនប៉ះពាល់ដល់សុភមង្គលនោះទេ ចំណែកឯបុរសវ័យចំណាស់ យល់ឃើញថា ការអត់ឱនដល់ការប្រព្រឹត្តអំពើហិង្សាដើម្បីអាច

---

[18] ប្រភេទនៃអំពើហិង្សាដ៏ធ្ងន់ធ្ងរបំផុតមានដូចជា ការវាយដំ ការគំរាមកំហែងដោយប្រើកាំបិត ឬកាំបិតផ្គាក់ ដុត ឬស្រោច និងជះទឹកអាស៊ីត ចាក់នឹងកាំបិត ឬបាញ់នឹងគ្រាប់កាំភ្លើងជាដើម។

[19] មានការទទួលស្គាល់ថា ប្តីវាយប្រពន្ធនៅពេលដែលប្រពន្ធចេញទៅក្រៅមិនបានប្រាប់ មិនបានមើលកូន ឈ្លោះជាមួយប្តី មិនព្រមរួមភេទជាមួយប្តី ឬធ្វើម្ហូបមិនឆ្ងាញ់។

រស់នៅជាមួយគ្នាក្នុងគ្រួសារបាន គឺមិនអាចទទួលយកបានឡើយ។ ទាំងក្មេងប្រុស និងក្មេងស្រីមានការព្រួយបារម្ភណ៍ថា កូននឹងអាចបែកគ្នាប្រសិនបើឪពុកម្តាយរបស់ពួកគេមិនអត់ធ្មត់ទាក់ទងនឹងអំពើហិង្សា។

នៅក្នុងការសិក្សារបស់កម្មវិធីភាពជាដៃគូសម្រាប់ការទប់ស្កាត់[20] បុរសដែលប្រព្រឹត្តិអំពើរំលោភសេពសន្ថវៈបានឱ្យដឹងថា មូលហេតុជំរុញឱ្យមានការរំលោភសេពសន្ថវៈ គឺដោយសារតែពួកគេចង់ប្រព្រឹត្តអំពើនេះ ពួកគេមានសិទ្ធិក្នុងការធ្វើរបៀបនេះ វាជាការកម្សាន្តសប្បាយ ឬគិតថានេះគឺជាការដាក់ទណ្ឌកម្មដល់ស្ត្រី។ មានបុរសតិចតួចណាស់ដែលទទួលផលវិបាកឬទណ្ឌកម្មផ្លូវច្បាប់ដោយសារវប្បធម៌ និទណ្ឌភាព។ នេះជាការខ្វះខាតក្នុងការដាក់ទណ្ឌកម្មផ្លូវច្បាប់ ឬសង្គម ឬការដាក់ទោសលើបុរស រួមជា មួយនឹងផ្នត់គំនិតដែលថា ស្ត្រីមួយចំនួន «មិនល្អ» ហើយសមនឹងទទួលទណ្ឌកម្មបែបនេះ បានធ្វើឱ្យឧក្រិដ្ឋកម្មទាំងនេះនៅបន្តកើតមាន ។

គោលគំនិតក្នុងចំណោមជនរងគ្រោះដោយសារអំពើហិង្សាដែលគិតថា ពួកគេជាអ្នកបង្កអំពើហិង្សានោះឡើងឬពួកគេធ្វើអ្វីមួយខុស បានបញ្ឈប់ជនរងគ្រោះទាំងនោះមិនឱ្យរាយការណ៍ពីបទឧក្រិដ្ឋនោះឡើយ។ ស្ត្រីទទួលរងការដាក់សម្ពាធដោយសារតែអាកប្បកិរិយាដែលពួកគេត្រូវតែអត់ធ្មត់ និងមិនត្រូវប្រាប់នរណាម្នាក់ឱ្យដឹងពីអំពើហិង្សា ជាពិសេសនៅក្នុងគ្រួសារ ដូចជាក្នុងចំណងអាពាហ៍ពិពាហ៍ ឬក្រុមគ្រួសារ។ អន្តរាគមន៍គោលនយោបាយស្តីពីការផ្តល់សេវា ត្រូវពិចារណាពីឥទ្ធិពលនៃអំណាចរវាងស្ត្រីនិងបុរសជាសមាជិកក្នុងគ្រួសារ និងក្នុងរង្វង់គ្រួសារដើម្បីផ្តល់សេវាដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។

អ្នកអនុវត្តច្បាប់និងអាជ្ញាធរពាក់ពន្ធ័បានប្រើប្រាស់ផ្នត់គំនិតយេនឌ័រ ក្នុងការចាត់ចែងករណីហិង្សាជាជាងការអនុវត្តច្បាប់។

## ស្ត្រីដែលទទួលបានមុខតំណែងនៅក្នុងការធ្វើសេចក្តីសម្រេចជាសាធារណៈមានការកើនឡើង ប៉ុន្តែនៅតែមានចំនួនតិចបើធៀបនឹងចំនួនបុរស

តាមផ្លូវច្បាប់ស្ត្រីមានសិទ្ធិស្មើបុរសទាក់ទងនឹងការចូលរួមក្នុងវិស័យនយោបាយ។ យ៉ាងណាក៏ដោយ ក៏នៅក្នុងការអនុវត្តន៍ជាក់ស្តែង ស្ត្រីប្រឈមនឹងការរើសអើងដោយផ្ទាល់

[20] Fulu, E., X. Warner, S. Miedema, R. Jewkes, T. Roselli and J. Lang (2013) *Why do some men use violence and how can we prevent it?* Bangkok: UN Women.



និងដោយប្រយោល ដោយសារតែផ្នត់គំនិតសង្គមបានដាក់សម្ពាធឱ្យស្ត្រីស្ថិតនៅក្រោមបង្គាប់ និងមិនសូវបានបង្ហាញពីគំនិតយោបល់របស់ខ្លួនជាសាធារណៈ។ ដោយសារតែគោលគំនិតទាំងនេះ ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ នៅមានកម្រិត ដោយមានស្ត្រី ២០% ជាសមាជិករដ្ឋសភា និងមានស្ត្រី ១៤% ជាសមាជិកព្រឹទ្ធសភា។ ចំនួននេះបានកើនឡើងក្នុង ២ទសវត្សរ៍កន្លងមក តែទោះជាយ៉ាងណាក៏ដោយ ក៏ចំនួនតំណាងស្ត្រីនៅមានកម្រិតនៅឡើយ ។

▲ ការផ្លាស់ប្តូរឥរិយាបថនាំមកនូវការកើនឡើងនៃការចុះឈ្មោះចូលរៀនរបស់ក្មេងស្រី

ជាមួយគ្នានេះដែរ ស្ត្រីនៅថ្នាក់ដឹកនាំឃុំ សង្កាត់មានការកើនឡើង ប៉ុន្តែចំនួននេះនៅតិចនៅឡើយ ដែលមិនអាចមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចសំខាន់ៗ។ ចំនួនតិចតួចនេះបណ្តាលមកពី គណបក្សនយោបាយមិនបានដាក់ចំនួនស្ត្រីឈរឈ្មោះ និងប្រជាពលរដ្ឋទូទៅពុំទាន់ទទួលស្គាល់ពេញលេញលើ ការដឹកនាំរបស់ស្ត្រី។

ផ្នត់គំនិតសង្គមដែលថា ស្ត្រីមានលក្ខណៈមិនគ្រប់គ្រាន់ក្នុងការចូលរួមក្នុងវិស័យនយោបាយនៅតែមាន ដែលជាមូលដ្ឋានមួយក្នុងការធ្វើឱ្យស្ត្រីក្លាយជាមនុស្សបន្ទាប់បន្សំ និងត្រូវបានបែងចែកនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចនៅមានកម្រិត។ ជំនឿជាប្រពៃណី ដែលមិនបានឱ្យតម្លៃលើសមត្ថភាព និងសក្តានុពលរបស់ស្ត្រី គឺជាឧបសគ្គដែលរារាំងក្នុងការចូលរួមយ៉ាងសកម្មរបស់ស្ត្រី។ ប្រការនេះពិតជាកើតមានសម្រាប់ស្ត្រីវ័យក្មេងដែលជឿថា ពួកគេមិនសូវមានសមត្ថភាពដូចបុរស ហើយមិនសូវសក្តិសមក្នុងមុខតំណែងសំខាន់ៗក្នុងវិស័យនយោបាយនិងអភិបាលកិច្ច[21] ។ ជាទូទៅ ស្ត្រីមានបទពិសោធន៍តិចក្នុងភាពជាអ្នកដឹកនាំ ការគ្រប់គ្រងនិងក្នុងវិស័យនយោបាយ។

ការគាំទ្រ និងការជំរុញលើកទឹកចិត្តពីសមាជិកគ្រួសារ និងសហគមន៍ គឺជាកត្តាសំខាន់ក្នុងការពង្រឹងការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ[22]។ ការរើសអើងលើស្ត្រីធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពទទួល បានមុខតំណែងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច ។

ការបញ្ជ្រាបយេនឌ័រត្រូវបានទទួលស្គាល់ថា ជាសកម្មភាពគន្លឹះជាអាទិភាព នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែការបញ្ជ្រាបយេនឌ័រក្នុងវិស័យផ្សេងៗជាច្រើនមិនទាន់បានល្អប្រសើរដោយសារ ការប្តេជ្ញាចិត្ត និងការគាំទ្រផ្សេងៗទៀតរួមទាំងបច្ចេកទេសនិងថវិកានៅមានកម្រិត។

## ស្ត្រីស្ថិតនៅក្នុងក្រុមដែលងាយរងគ្រោះ ប្រឈមនឹងការរើសអើងកាន់តែខ្លាំង ប៉ុន្តែបញ្ហានេះពុំទាន់បានយកមកពិចារណាឱ្យបានល្អិតល្អន់នៅក្នុងការពិភាក្សាអំពីគោលនយោបាយ

ស្ត្រី និងកុមារីដែលស្ថិតក្នុងក្រុមបាត់បង់ឱកាស ឬងាយរងគ្រោះ ដូចជាពិការ ចាស់ជរា ជនជាតិដើមភាគតិច និងក្រុមស្រលាញ់ភេទដូចគ្នាជាដើម ជារឿយៗប្រឈមនឹងទម្រង់ជាច្រើននៃការរើសអើង។ ភាពងាយរងគ្រោះកាន់តែមានការកើនឡើង ដោយសារស្ថានភាពសង្គម សេដ្ឋកិច្ចរបស់ពួកគេ។ លទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានសេវាសុខាភិបាលមូលដ្ឋាន សេវាអប់រំ និងសេវាផ្លូវច្បាប់ គឺមានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។ ស្ត្រីដែលមានភាពងាយរងគ្រោះជួបការលំបាកកាន់តែធ្ងន់ធ្ងរក្នុង

[21] Ministry of Women's Affairs (2011) *Report on Study of emerging gender issues among women, girls and youth in Cambodia.* Phnom Penh.

[22] Ibid.

ការស្វែងរកការងារសមរម្យ ដោយសារការរើសអើងលើភេទ ពិការភាព និងប្រវត្តិជាតិកំណើត និងលទ្ធភាពទទួលបានសេវានានារបស់ពួកគេនៅមានកម្រិត។ ដើម្បីគាំទ្រដល់ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី វិធានការផ្លូវច្បាប់ជាក់លាក់ និងកម្រិតគោលនយោបាយដូចជាវិធានការជាវិជ្ជមាន និងចំណុចដៅ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការធានាឱ្យមានការបញ្ចូលស្ត្រីមកពីក្រុមបាត់បង់ឱកាសទៅក្នុងវិស័យសាធារណៈ និងឯកជន។

ផ្នត់គំនិតសង្គម បានដាក់គំនាបលើស្ត្រីដែលមានប្រវត្តិខុសៗគ្នា ដូចជាវណ្ណៈ អាយុ ពិការភាព ជាតិពិន្ទុ និងនិន្នាការផ្លូវភេទ។ តម្រូវការខុសៗគ្នារបស់ស្ត្រីដែលមានភាពងាយរងគ្រោះទាំងនេះ ទទួលបានការយកចិត្តទុកដាក់នៅមានកម្រិតនៅឡើយ។ ការស្រាវជ្រាវផ្អែកតាមភស្តុតាង គឺមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យមានការយកចិត្តទុកដាក់ដល់រាល់ការបញ្ចេញមតិ និងការលើកឡើងនូវបញ្ហារបស់ពួកគេ និងដើម្បីធានាឱ្យមានការឆ្លើយតបកម្រិតគោលនយោបាយសមស្រប។កង្វះខាតទិន្នន័យនិងស្ថិតិច្បាស់លាស់នៅក្នុងការវិភាគស៊ីជម្រៅពីភាពងាយរងគ្រោះរបស់ពួកគេធ្វើឱ្យអ្នកតាក់តែងគោលនយោបាយមិនអាចធ្វើអន្តរាគមន៍ដល់រាល់បញ្ហាកើតឡើងប្រកបដោយប្រសិទ្ធភាពនោះឡើយ។

ការរើសអើងលើស្ត្រីប្តូរភេទ និងស្រីស្រឡាញ់ស្រី ត្រូវបានរាយការណ៍មកថា ជារឿងដដែលមួយកើតមានជាញឹកញាប់[23]។ ក្រុមអ្នកស្រលាញ់ភេទដូចគ្នា ជាពិសេស ស្ត្រីស្រឡាញ់ស្ត្រី ត្រូវបានបង្ខំឱ្យគោរពតាមផ្នត់គំនិតសង្គមដែលរើសអើងចំពោះអ្នកដែលស្ថិតនៅក្រៅបទដ្ឋានសង្គម ។ ការផាត់ចេញដោយ សមាជិកគ្រួសារ និងសហគមន៍បង្កើនភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចដល់អ្នកទាំងនោះកាន់តែខ្លាំង និងរារាំងនូវលទ្ធភាពទទួលបានសេវាសុខាភិបាល។ ពួកគេបានប្រឈមនឹងទម្រង់នៃការរើសអើងយ៉ាងច្រើន ដែលអាចបង្ខំឱ្យពួកគេសម្រេចចិត្តធ្វើការជាអ្នករកស៊ីផ្លូវភេទ។ ទម្រង់នៃការរើសអើងពីសង្គមគឺជាឧបសគ្គដ៏ចម្បងមួយ ហើយការបញ្ចេញមតិរបស់ពួកគេពុំទាន់ត្រូវបានយកចិត្តទុកដាក់ក្នុងកិច្ចពិគ្រោះយោបល់លើគោលនយោបាយសាធារណៈនៅឡើយ[24] ។

---

[23] Jarrett Davis, H. L. ,2014, *"More than gender: A baseline study of transgender persons in the Phnom Penh sex industry"*. Phnom Penh: LOVE146

[24] Vicente S. Salas, MD, MPH, and Srun Sorn, 2013, *An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities in Some Areas of Cambodia and Their Ways of Coping"*, Phnom Penh: SPCU-CARD Press

ស្ត្រី និងក្មេងស្រី ជាពិសេសក្រុមស្ត្រីដែលងាយរងគ្រោះ ដូចជាស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីពិការ ស្ត្រីមានបន្ទុកច្រើនក្នុងគ្រួសារ ចាស់ជរា ជនជាតិដើមភាគតិចជាដើម ប្រឈមនឹងឧបសគ្គជាច្រើន ប៉ុន្តែការឆ្លើយតបគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីដើម្បីដោះស្រាយនិងឆ្លើយតបបញ្ហាទាំងនោះនៅមានកម្រិត។

ស្ត្រី(អាយុពី១៥-៦៤ឆ្នាំ)ដែលមានការងារធ្វើទូទាំងប្រទេសកម្ពុជាមាន(៥៣%) និងច្រើនជាងនេះនៅក្នុងតំបន់ជនបទ (៦៣%)។ ស្ត្រីទាំងនេះធ្វើការនៅក្នុងវិស័យចម្បងៗ (primary) ដូចជាវិស័យកសិកម្ម វិស័យព្រៃឈើ និងវិស័យជលផល ដែលត្រូវបានកំណត់តាមរយៈផលិតភាពទាប ហើយទទួលបានមកវិញនូវប្រាក់កម្រៃទាបសម្រាប់ស្ត្រី[25] ។ ស្ត្រីរស់នៅក្នុងតំបន់ជនបទប្រឈមនឹងលទ្ធភាពទទួលបាននូវធនធានសំខាន់ៗ ដូចជាចំណេះដឹង ជំនាញ បច្ចេកទេស និងសេវាផ្សេងៗសម្រាប់ផលិតផលកសិកម្ម ដោយសារផ្នត់គំនិតសង្គមដែលរើសអើងលើស្ត្រី។ ការទទួលបានកម្មសិទ្ធិដីធ្លីរបស់ស្ត្រីនៅមានកម្រិត (ស្ត្រី១៨%)[26] ហើយស្ត្រីមួយចំនួនតូចមានលទ្ធភាពទិញដីដោយប្រើប្រាស់ឈ្មោះរបស់ខ្លួនដោយសារតែបទដ្ឋានសង្គម ឧបសគ្គហិរញ្ញវត្ថុ និងនីតិវិធីរដ្ឋបាល។ ទោះជាយ៉ាងក៏ដោយក៏ផលប៉ះពាល់នៃផ្នត់គំនិត និងឥរិយាបថសង្គមទៅលើតួនាទីនិងបទពិសោធន៍របស់ស្ត្រីមិនត្រូវបានចងក្រងជាឯកសារឱ្យបានត្រឹមត្រូវឡើយ ដូច្នេះបញ្ហាតម្រូវការ និងការបញ្ចេញមតិរបស់ស្ត្រីក៏មិនត្រូវបានឆ្លុះបញ្ចាំង និងឆ្លើយតបក្នុងគោលនយោបាយដែរ។

ស្ត្រីក្រីក្រជាមេគ្រួសារដែលមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រចំណាត់ទី១មានចំនួន ៣៧,៦% និងស្ត្រីក្រីក្រជាមេគ្រួសារដែលមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រចំណាត់ថ្នាក់ទី២ មានចំនួន៣១.៤%។ ផ្នត់គំនិត និងឥរិយាបថសង្គមទាក់ទងនឹងតួនាទីរបស់បុរស ស្ត្រី បានធ្វើឱ្យមានផលប៉ះពាល់ថែមទៀត នៅពេលដែលមានគ្រោះទឹកជំនន់កើតឡើង។ ស្ត្រីភាគច្រើនមិនអាចចាកចោលផ្ទះនិងបោះបង់សមាជិកក្នុងគ្រួសារបានឡើយ ហើយក៏មានការលំបាកក្នុងការធ្វើបម្លាស់ទី ដោយសារតែបន្ទុកការងារ និងការទទួលខុសត្រូវទ្វេដង។ បញ្ហាខាងលើនេះ ធ្វើឱ្យស្ត្រីងាយរងគ្រោះច្រើនជាងបុរស នៅពេលដែលមានការប្រែប្រួលអាកាសធាតុកើតឡើង ជាពិសេសគ្រោះទឹកជំនន់។ ប្រការនេះទាមទារ ឱ្យមានការយកចិត្តទុកដាក់នៅកម្រិតគោលនយោបាយមួយ ដើម្បីបង្កើនការយល់ដឹងពីការចែករំលែកការងារ

[25] National Institute of Statistics, Ministry of Planning (2012) *Cambodia Socio-Economic Survey*. Phnom Penh.

[26] National Institute of Statistics, Ministry of Planning (2012) *Cambodia Socio-Economic Survey*. Phnom Penh.

ផ្ទះសម្បែងក្នុងគ្រួសារប្រកបដោយសមធម៌[27] ។

ស្ត្រីមានផ្ទៃពោះមួយចំនួន មានភាពងាយរងគ្រោះថែមទៀតក្នុងការទទួលបានសេវាសុខភាពនៅពេលដែលមានទឹកជំនន់កើតឡើង និងមានការលំបាកក្នុងការធ្វើដំណើរទៅមណ្ឌលសុខភាព ដែលធ្វើឱ្យស្ត្រី កាន់តែប្រឈមទៅនឹងហានិភ័យបន្ថែមទៀត ក្នុងពេលដែលស្ត្រីត្រូវសម្រាលកូននៅផ្ទះ[28]។ នៅពេលដែលមានការប្រែប្រួលអាកាសធាតុកើតឡើង ស្ត្រី និងកុមារីងាយទទួលរងផលប៉ះពាល់ដែលកើតឡើងពីជំងឺឆ្លងតាមទឹកជំនន់ រាំងស្ងួត ដូចជាជំងឺភ្នែកក្រហម សើស្បែក រាគរូស ដោយសារតែកាយសម្បទាខ្សោយ ខ្វះអនាម័យ ខ្វះទឹកស្អាតប្រើប្រាស់ ក្នុងខណៈពេលដែលស្ត្រីជាអ្នកថែទាំផ្ទះ និងគ្រួសារ រីឯបុរសជាអ្នករកចំណូលខាងក្រៅផ្ទះ។

ដោយសារតែស្ត្រីត្រូវបានគេទទួលស្គាល់ថា មានតួនាទី ចំណេះដឹង ព្រមទាំងការទទួលខុសត្រូវរួចស្រេចទៅហើយនៅក្នុងផ្នែកថាមពល អនាម័យ ការគ្រប់គ្រងកាកសំណល់ និងការបង្កបង្កើនផលជុំវិញផ្ទះនោះ ដូច្នេះស្ត្រីស្ថិតក្នុងស្ថានភាពល្អបំផុតមួយក្នុងការជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ការទទួល បានព័ត៌មានប្រកបដោយសមធម៌ និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់ពួកគាត់អាចធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ ដូចជាសុខភាពគ្រួសារ អាហារូបត្ថម្ភ ការអប់រំ និងជាចុងក្រោយអាចចូលរួមកាត់បន្ថយផលប៉ះពាល់ដែលបណ្ដាលពីការប្រែប្រួលអាកាសធាតុចំពោះក្រុមគ្រួសារ ក៏ដូចជាសហគមន៍ទាំងមូល ដើម្បីកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងគោលនយោបាយ។

ជនជាតិភាគតិចដែលប្រើប្រាស់ភាសាកំណើតរបស់ពួកគេ ទទួលបានការចូលរួមក្នុងអភិបាលកិច្ចមូល ដ្ឋាន ការអប់រំ ព័ត៌មាន ស្តីពីមេរោគអេដស៍ និងសុខភាពបន្តពូជនៅមានកម្រិតនៅឡើយ។ ខណៈដែល មណ្ឌលសុខភាព សាលារៀនត្រូវបានបង្កើតឡើង ប៉ុន្តែជារឿយៗមានបុគ្គលិកមិនគ្រប់គ្រាន់ឬ មិនមាន លទ្ធភាពធ្វើទំនាក់ទំនងជាមួយជនជាតិដើមភាគតិចទាំងនោះ ។

---

27 របាការណ៏សិក្សាពីការស្តារឡើងវិញក្រោយទឹកជំនន់របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឆ្នាំ២០១៤

28 Ibid.

## «លក្ខណៈឯកជន» បន្តកម្រិតសេរីភាពរបស់ស្ត្រី ក្នុងការធ្វើអន្តរាគមន៍នៅក្នុងបញ្ហាគ្រួសារ

ផ្នត់គំនិត និងឥរិយាបថសង្គមនៅតែផ្តល់បុព្វសិទ្ធិដល់បុរសស្ទើរគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅក្នុងគ្រួសារនិងសង្គម។ បញ្ហានេះបានផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ជីវិតរស់នៅរបស់ស្ត្រីផងដែរ។ ទស្សនៈបានលើកឡើងថា បុរសគួរធ្វើជាអ្នកដឹកនាំ និងជាអ្នកការពារនៅតែបន្តមាននៅក្នុងសង្គម។ ការសិក្សារបស់អង្គការយេនឌ័រ និងអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០១០ បានបញ្ជាក់ថា បុរសមួយចំនួនប្រកាន់នូវគោលគំនិតថា បុរសគួរបំពេញតួនាទីជាមេគ្រួសារជាអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុក្នុងគ្រួសារ និងគ្រប់គ្រងស្ត្រី។ ជាធម្មតាការដែលស្ត្រីឱ្យបុរសមានបុព្វសិទ្ធិគ្រប់គ្រងលើស្ត្រីក៏ជាបញ្ហាមួយផងដែរ។ វិធានការឆ្លើយតបដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៃភាពជាបុរស ក្នុងជីវិតឯកជនមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យសម្រេចបាននូវទំនាក់ទំនងដែលមានការគោរពគ្នាទៅវិញទៅមក។

ស្ត្រីមួយចំនួនមិនមានទំនុកចិត្តលើសមត្ថភាពរបស់ខ្លួនដោយសារតែផ្នត់គំនិត និងឥរិយាបថសង្គម។ តាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០ បានបង្ហាញថា ស្ត្រីភាគច្រើនមិនជឿថា ប្រពន្ធគួរមានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួនឡើយ។ ការសិក្សារបស់កម្មវិធីភាពជាដៃគូដើម្បីការទប់ស្កាត់ឆ្នាំ២០១៣ ក៏បានរកឃើញផងដែរថា មានបុរស ៦២.៦% និងស្ត្រី ៥៧.១% យល់ស្របថា បុរសគួរជាអ្នកសម្រេចចិត្តចុងក្រោយគ្រប់បញ្ហាគ្រួសារទាំងអស់ ហើយបុរសនិងស្ត្រីជឿថា បុរសមានសិទ្ធិធ្វើជាអ្នកសម្រេចចិត្តដ៏សំខាន់ក្នុងគ្រួសាររបស់ខ្លួន[29] ។ ការពឹងផ្អែករបស់ស្ត្រីលើស្វាមីនៅក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យឯកជនមិនអាចមើលឃើញឡើយ ក៏ប៉ុន្តែបានឆ្លុះបញ្ចាំងពីកម្រិតនៃភាពក្លាហាន និងភាពជឿជាក់របស់ស្ត្រី ក្នុងការចូលរួមធ្វើសេចក្តីសម្រេចនៅក្នុងវិស័យសាធារណៈ។

អាពាហ៍ពិពាហ៍ដោយបង្ខំនៅតែកើតមាន ហើយនៅពេលដែលបានរៀបការជាប្តីប្រពន្ធមានការដាក់សម្ពាធយ៉ាងខ្លាំងលើពួកគេឱ្យរក្សាឱ្យបាននូវចំណងអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក៏ដោយ ក៏អាកប្បកិរិយាចំពោះអាពាហ៍ពិពាហ៍មានការផ្លាស់ប្តូរ ហើយភាគរយនៃស្ត្រីដែលគ្រួសាររបស់ខ្លួនបានរៀបចំអាពាហ៍ពិពាហ៍ មានការធ្លាក់ចុះពី៥១%ក្នុងឆ្នាំ២០០០ ទៅ៣៥%ក្នុងឆ្នាំ២០០៥[30] ។ ទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍ពីវ័យក្មេងនៅតែកើតមាន

---

[29] អង្កេតតាមដានស្តីពីអំពើហិង្សាលើស្ត្រី ក្រសួងកិច្ចការនារី ឆ្នាំ២០០៩

[30] អង្កេតវិទ្យាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០៥

ហើយឪពុកម្តាយមួយចំនួនបានដាក់សម្ពាធលើកូនស្រីឱ្យរៀបការជាមួយបុរសដែលគាត់បានជ្រើសរើសតាំងពីនាងនៅក្មេង។

ការលែងលះ គឺត្រូវបានចាត់ទុកថាជាទង្វើដ៏គួរឱ្យអៀនខ្មាស់ ជាពិសេសប្រសិនបើស្ត្រីជាអ្នកផ្តើមគំនិតលែងលះ។ ជារឿយៗ ការលែងលះបានដាក់ស្ត្រីទៅក្នុងស្ថានភាពមួយកាន់តែងាយរងគ្រោះ ដោយសារតែពួកគេអាចខ្វះសមត្ថភាពក្នុងការទាមទារសិទ្ធិទទួលបានទ្រព្យសម្បត្តិរបស់ខ្លួន និងការអនុវត្តន៍ ទាក់ទងនឹងអាហារកិច្ចមិនបានអនុវត្តសមស្រប[31]។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមិនទាន់មានការសិក្សាស្រាវជ្រាវដែលផ្តល់ការវិភាគពីការលែងលះ និងផលវិបាកនៃការលែងលះដែលកើតចេញពីឥទ្ធិពលយេនឌ័រ និងវិសមភាពក្នុងទំនាក់ទំនងយេនឌ័រឡើយ។ ឧបសគ្គដាក់លាក់របស់ស្ត្រី និងការមាក់ងាយជុំវិញបញ្ហាលែងលះនៅតែមិនទាន់ដឹងច្បាស់ ហើយត្រូវធ្វើការស្រាវជ្រាវដើម្បីជំរុញគោលនយោបាយឱ្យធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពសម្រាប់អត្ថប្រយោជន៍របស់ស្ត្រី និងកូន ដែលងាយរងគ្រោះពាក់ព័ន្ធទៅនឹងបញ្ហាការទទួលកេរ្តិ៍មរតក ទ្រព្យជាកម្មសិទ្ធិ និងទ្រព្យសម្បត្តិ ព្រមទាំងទទួលរងការរើសអើងក្នុងសង្គម និងក្លាយជាកូនដែលមានតែម្តាយ។

ប្រទេសកម្ពុជានៅតែស្ថិតនៅក្នុងអន្តរកាលផ្នែកប្រព័ន្ធច្បាប់ដែលខ្ទេចខ្ទាំដោយសារសង្គ្រាម ហើយមានច្បាប់ថ្មីជាច្រើនត្រូវបានអនុម័តក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ វត្តមានភាពនៃច្បាប់ដើម្បីការពារស្ត្រី គឺមានសារៈសំខាន់ណាស់ ក៏ប៉ុន្តែច្បាប់ត្រូវតែភ្ជាប់មកជាមួយនូវការផ្លាស់ប្តូរអាកប្បកិរិយាក្នុងសង្គម ដើម្បីធ្វើឱ្យសមភាពយេនឌ័រមានតថភាពជាក់ស្តែង[32]។ ក្រមរដ្ឋប្បវេណីថ្មីដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៧ ត្រូវបានគេរំពឹងថានឹងផ្តល់កិច្ចគាំពារដ៏ប្រសើរដល់សិទ្ធិស្ត្រីក្នុងកិច្ចការរដ្ឋប្បវេណី ដោយបង្កើតជាគោលការណ៍ស្របច្បាប់នៃសមភាពរវាងបុរសនិងស្ត្រី ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា៦ នៃក្រមរដ្ឋប្បវេណីពាក់ព័ន្ធនឹង "គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ" បានចែងថា «រូបវន្តបុគ្គលគ្រប់រូបមានសិទ្ធិនិងកាតព្វកិច្ចក្នុងនាមរបស់ខ្លួន»។ បទប្បញ្ញត្តិនេះត្រូវប្រើប្រាស់យ៉ាងត្រឹមត្រូវដោយតុលាការ ហើយអង្គភាពយុត្តិធម៌ត្រូវជួយធានាឱ្យមានសមភាពពេញលេញរវាងស្ត្រីនិង បុរស ក្នុងគ្រប់កិច្ចការរដ្ឋប្បវេណីទាំងអស់។

---

[31] NGO CEDAW, 2006, *"The Cambodia Shadow report to the UN CEDAW Committee"*, Phnom Penh

[32] Plischuk, M, 2012, *"Women and law in Cambodia"*, in Introduction to Cambodian Law, Konrad Adenauer Stiftung, Phnom Penh

## ការប្រើប្រាស់ប្រព័ន្ធព័ត៌មាន ទំនាក់ទំនង និងបច្ចេកវិទ្យា (ICT) ក្នុងចំណោមស្ត្រី មានការរីកចម្រើនជាលំដាប់ ក៏ប៉ុន្តែអន្តរាគមន៍ពីគោលនយោបាយនៅមានកម្រិតនៅឡើយក្នុងការធ្វើឱ្យមានការកែប្រែអាកប្បកិរិយា និងសង្គមប្រកបដោយប្រសិទ្ធភាព

ទូរស័ព្ទចល័តបានក្លាយជាឧបករណ៍ធ្វើឱ្យមានការផ្លាស់ប្តូរកែប្រែក្នុងសង្គមកម្ពុជា។ ប្រជាជនច្រើនជាង ៩០% មានទូរស័ព្ទចល័តប្រើប្រាស់ និងប្រហែលជាពាក់កណ្តាលមានទូរស័ព្ទផ្ទាល់ខ្លួន[33] ។ ទូរស័ព្ទចល័តមានលក្ខណៈសម្ងាត់ជាឯកជនជាងវិធីសាស្ត្រទំនាក់ទំនងបែបបុរាណ។ ទូរស័ព្ទអាចបង្កើនលទ្ធភាពដល់ស្ត្រីក្នុងទំនាក់ទំនងឯកជនជាមួយអ្នកផ្សេងទៀតពីបញ្ហាផ្ទាល់ខ្លួន ដូចជាបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ បញ្ហាសេដ្ឋកិច្ចគ្រួសារ ការប្រឆាំងរាល់ទម្រង់នៃអំពើហិង្សា ដែលមិនអាចពិភាក្សាដោយបើកចំហរនៅកន្លែងទូទៅឡើយ។ ស្ត្រីច្រើនជាងបុរស ជាពិសេសស្ត្រីដែលមានការអប់រំ ស្ត្រីវ័យក្មេង ស្ត្រីរស់នៅទីក្រុងមានទូរស័ព្ទទំនើបប្រើ ដែលអាចឱ្យពួកគេសរសេរអក្សរជាភាសាខ្មែរលើទូរស័ព្ទ[34] ។ ដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី មានឱកាសជាច្រើនតាមរយៈការប្រើប្រាស់ទូរស័ព្ទ ប៉ុន្តែពុំទាន់មានការឆ្លើយតបក្នុងកម្រិតគោលនយោបាយជាប្រព័ន្ធបានផ្តួចផ្តើមទេ ដោយសារតែមិនទាន់មានគោលនយោបាយ ស្តីពីប្រព័ន្ធព័ត៌មាន ទូរគមនាគមន៍ និងបច្ចេកវិទ្យានៅឡើយ។

បណ្តាញសង្គម ដូចជា Facebook Twitter និង blogging ជាដើម ដែលមានភាពពេញនិយមក្នុងចំណោមស្ត្រីវ័យក្មេង គឺជាឧបករណ៍ទំនាក់ទំនងក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រីសម្រាប់ប្រើប្រាស់ក្នុងគោលបំណងជាច្រើន។ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ស្ត្រីអាចរៀបរាប់ពីបញ្ហាឯកជនជាមួយស្ត្រីផ្សេងទៀតដោយមិនបញ្ចេញឈ្មោះ។ នៅកម្ពុជា ស្ត្រីពេញវ័យចំនួន១៤% បានប្រើប្រាស់បណ្តាញសង្គម Facebook (២៩%នៃបុរស) ហើយក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាលដែលយកចិត្តទុកដាក់លើយេនឌ័រមួយចំនួនបានបង្កើតទំព័រ Facebook ផ្ទាល់ខ្លួនដើម្បីផ្សព្វផ្សាយសកម្មភាពរបស់ខ្លួន និងលើកកម្ពស់ការយល់ដឹងផ្សេងៗ។ ជាមួយនឹងសេរីភាពក្នុងការបញ្ចេញមតិ គោលការណ៍អន្តរាគមន៍ជាក់លាក់មួយ ស្តីពីប្រព័ន្ធផ្សព្វផ្សាយសង្គម អាចធ្វើឱ្យមានការផ្លាស់ប្តូរគោលគំនិតវិជ្ជមានសម្រាប់ជាសក្តានុពលរបស់ស្ត្រីឱ្យក្លាយជាអ្នកដឹកនាំ។

---

33 USAID, 201, "*RAPID ASSESSMENT O F THE POLITICAL, LEGAL ANDINSTITUTIONAL SETTING CAMBODIA*", Phnom Penh

34 Kimchhoy, P. et.al, 2013, *"Existence and Use of Phones that permit written communication in Khmer Script"*, Open Institute, Phnom Penh

ប្រព័ន្ធផ្សព្វផ្សាយសង្គមចូលរួមចំណែកគាំទ្រការបង្កើតអត្តសញ្ញាណយេនឌ័ររបស់ស្ត្រី និងអាចធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងការទំនាក់ទំនង និងឥរិយាបថយេនឌ័រ តាមរយៈការលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាស្ត្រី។ អ្នកដឹកនាំជាស្ត្រីវ័យក្មេងមួយចំនួនមានវត្តមានតាមរយៈបណ្តាញសង្គម Facebook ដែលផ្តល់ឱកាសដល់ពួកគេក្នុងការបង្ហាញពីខ្លួនឯង និងចែករំលែកសេចក្តីប៉ងប្រាថ្នារបស់ខ្លួន និងគោលបំណងក្នុងការផ្លាស់ប្តូរ។

ប្រព័ន្ធផ្សព្វផ្សាយអាចគាំទ្រការផ្តល់ភាពអង់អាចដល់ស្ត្រីតាមរបៀបជាច្រើន។ ការទទួលបានប្រព័ន្ធផ្សព្វផ្សាយ គឺមានកម្រិតខ្ពស់សម្រាប់ស្ត្រីកម្ពុជា។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១០ បានរកឃើញថា ស្ត្រី៦៨%អាចចូលទៅកាន់ប្រព័ន្ធផ្សព្វផ្សាយរៀងរាល់សប្តាហ៍។ ការទទួលបានប្រព័ន្ធផ្សព្វផ្សាយជំរុញឱ្យស្ត្រីទទួលបានព័ត៌មានកាន់តែច្រើន ស្តីពីសុខភាព ការអប់រំ ប្រជាធិបតេយ្យ និងសិទ្ធិស្ត្រី។ ប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលខ្លាំងជាងការអប់រំក្នុងប្រព័ន្ធក្នុងការផ្សព្វផ្សាយ ទទួលបានចំណេះដឹងពីសិទ្ធិស្ត្រី[35]។ ក្រសួងកិច្ចការនារី បានដំណើរការកម្មវិធីវិទ្យុ ស្តីពីសិទ្ធិស្ត្រី និងសមភាពយេនឌ័រដែលមានឈ្មោះថាកម្មវិធី «នារីរតនៈ»។

[35] National Institute of Statistics, Ministry of Planning, Directorate General for Health, Ministry of Health (2010) *Cambodia Demographic and Health Survey.* Phnom Penh, Cambodia.

## អនុសាសន៍សម្រាប់គោលនយោបាយ

| ១. ការចូលរួមក្នុងផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីមានកម្រិតខ្ពស់ ក៏ប៉ុន្តែផ្នត់គំនិតសង្គមរារាំងស្ត្រីក្នុងការពង្រីកឱកាសរបស់ខ្លួន | |
|---|---|
| • បង្កើនការយកចិត្តទុកដាក់ក្នុងកម្រិតគោលនយោបាយ ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតសង្គម និងផ្តល់លទ្ធិភាពដល់ស្ត្រីក្នុងការពង្រីកឱកាសសេដ្ឋកិច្ចរបស់ខ្លួន។ អន្តរាគមន៍ប្រភេទនេះត្រូវកំណត់គោលដៅទៅលើឪពុកម្តាយ អាណាព្យាបាល អ្នកអប់រំ សហគមន៍ និងវិស័យឯកជន ដើម្បីគាំទ្រដល់ស្ត្រី ព្រមទាំងជំរុញឱ្យមានកិច្ចសហការជាមួយសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ[37] | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងផែនការ<br>-ក្រសួងរៀបចំដែនដី នគរូនីយកម្ម សំណង់ និងសូរិយោដី<br>-ក្រសួងរ៉ែ និងថាមពល<br>-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>-ក្រសួងអភិវឌ្ឍន៍ជនបទ<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>-ក្រសួងពាណិជ្ជកម្ម |
| • រាល់យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី សមភាព និងសមធម៌យេនឌ័រ អន្តរាគមន៍គោលនយោបាយ គួររួមបញ្ចូលជាប្រព័ន្ធនូវខ្លឹមសារច្បាស់លាស់ស្តីពីសក្តានុពលរបស់ស្ត្រី និងក្មេងស្រីក្នុងការពង្រីកសេដ្ឋកិច្ច ដើម្បីធ្វើឱ្យមានបម្លាស់ប្តូរជាវិជ្ជមាននូវ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងផែនការ |

[37] *Convention on the Elimination of All forms of Discrimination against Women* (CEDAW) 19b.

| | |
|---|---|
| ផ្តត់គំនិត និងអាកប្បកិរិយាដែលបច្ចុប្បន្នបណ្តាលឱ្យមានការរើសអើងលើស្ត្រី។ | -ក្រសួងរៀបចំដែនដី នគរូនីយកម្ម សំណង់ និងសុរិយោដី<br>-ក្រសួងរ៉ែ និងថាមពល<br>-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម<br>-ក្រសួងអភិវឌ្ឍន៍ជនបទ<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា<br>-ក្រសួងពាណិជ្ជកម្ម<br>-ក្រសួងព័ត៌មាន<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

## ២. ពង្រីកឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញបន្ថែមទៀតដល់ក្មេងស្រី ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ពួកគេ

- គួរជំរុញវិធានការនានាសំដៅធានាប្រសិទ្ធភាពរក្សាស្ត្រី និងកុមារីឱ្យបន្តការសិក្សា ជាពិសេសពីកម្រិតបឋមទៅមធ្យមសិក្សា និងនៅកម្រិតឧត្តមសិក្សា[38] ។
- លើកទឹកចិត្តឪពុកម្តាយ អាណាព្យាបាល សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ឱ្យទទួលស្គាល់ពីសារៈសំខាន់ នៃការសិក្សារបស់ កូនស្រី ថាជាការវិនិយោគរយៈពេលវែងសម្រាប់អនាគត ដោយបង្ហាញគំរូល្អរបស់អ្នកដឹកនាំជាស្ត្រី ដែលលេចធ្លោក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។

[38] CEDAW 33b.

| | |
|---|---|
| | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងព័ត៌មាន<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>-សង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍<br>-រដ្ឋបាលថ្នាក់ក្រោមជាតិ |
| • បញ្ចូលទៅក្នុងផែនការនារីរតនៈទី៤ នូវយុទ្ធសាស្ត្រទំនាក់ទំនងដ៏ទូលំទូលាយមួយ សំដៅបន្តលុបបំបាត់អាកប្បកិរិយា និងផ្នត់គំនិតរើសអើងលើស្ត្រី[39]។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី |
| • ពង្រឹងគុណភាព និងប្រសិទ្ធភាពការងារបញ្ជ្រាបយេនឌ័រ និងការអនុវត្តន៍គោលនយោបាយយេនឌ័រនៅក្នុងជួរមន្ត្រីអប់រំ ពីថ្នាក់ជាតិ រហូតដល់ក្រោមជាតិ និងក្នុងកម្មវិធីសិក្សា សំដៅធ្វើយ៉ាងណាកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងសង្គម ក៏ដូចជាលើកកម្ពស់ភាពអង់អាចដល់ស្ត្រី។ | -គ.ជ.ស.ស.ខ<br>-ក្រសួងអប់រំ យុវជន និងកីឡា |
| **៣. បន្តពង្រឹង និងពង្រីកលទ្ធភាពនៃការទទួលបានសេវាសុខភាពបន្តពូជដល់ស្ត្រី និងក្មេងស្រី ជាពិសេសនៅតំបន់ដាច់ស្រយាល** | |
| • ផ្តោតកិច្ចខិតខំប្រឹងប្រែងនៅកម្រិតគោលនយោបាយដើម្បីបង្កើនការផ្តល់ព័ត៌មាននិងសេវាសុខភាពផ្លូវភេទ និង សុខភាពបន្តពូជដល់ស្ត្រី រួមទាំងមធ្យោបាយពន្យារកំណើតទំនើបជាពិសេសសម្រាប់ស្ត្រីរស់នៅតំបន់ជនបទ[40]។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងសុខាភិបាល<br>-ក្រសួងព័ត៌មាន |

[39] CEDAW 19a.
[40] CEDAW 37.

| | |
|---|---|
| | -ក្រសួងអភិវឌ្ឍន៍ជនបទ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| • ការដាក់តែងគោលនយោបាយនានាគួរបន្ថែមការបញ្ចូលនូវវិធានការផ្សព្វផ្សាយព័ត៌មាន ជាពិសេសផ្តោតលើការកែប្រែទស្សនៈ និង ឥរិយាបថក្នុងចំណោមស្ត្រី ដើម្បីឱ្យស្ត្រីអាចពិភាក្សាពីបញ្ហាផ្លូវភេទ ដោយបើកចំហ។ ថវិកាគួរត្រូវបានបែងចែកឱ្យបានគ្រប់គ្រាន់ និងមានការប្រើប្រាស់យ៉ាងពេញលេញ សម្រាប់កម្មវិធីទំនាក់ទំនងព័ត៌មាន និងបច្ចេកវិទ្យា (ITC) ជាពិសេស ផ្តោតទៅលើស្ត្រីរស់នៅតំបន់ជនបទ។ | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-សង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍ |
| • បង្កើនការស្រាវជ្រាវបន្ថែមទៀតពាក់ព័ន្ធនឹងរបកគំហើញអំពីមូលហេតុចម្បងៗនៃកង្វះអាហារូបត្ថម្ភរបស់ស្ត្រី។ ការស្រាវជ្រាវនេះចាំបាច់ត្រូវធ្វើឡើងតាមរយៈទស្សនៈយេនឌ័រ ដើម្បីប៉ាន់ប្រមាណអំពីឥរិយាបថ និងបទដ្ឋានយេនឌ័រដែលមានការរើសអើងលើស្ត្រី ដែលនាំឱ្យមានផលប៉ះពាល់ដល់សុខភាពអាហារូបត្ថម្ភរបស់របស់ពួកគេ។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងសុខាភិបាល |
| • ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ស្តីពីសុខភាពផ្លូវភេទ នៅក្នុងកម្មវិធីសិក្សា និងបង្កើនបរិមាណសៀវភៅអានបន្ថែមនៅតាមគ្រឹះស្ថានសិក្សា។ | -គ.ជ.ស.ស.ខ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងកិច្ចការនារី<br>ក្រសួងសុខាភិបាល |

## ៤. បន្តពង្រីកផ្នត់គំនិត និងឥរិយាបថវិជ្ជមាន ទាក់ទងនឹងរឿងរ៉ាវផ្លូវភេទរបស់ស្ត្រី ក្នុងការរួមចំណែកទប់ស្កាត់ការឆ្លងមេរោគអេដស៍

| | |
|---|---|
| • បន្តជំរុញឱ្យមានកម្មវិធីដែលមានបំណងបង្កើនការយល់ដឹងអំពីសិទ្ធិនិង សុខភាពបន្តពូជរបស់ស្ត្រី តាមរយៈយុទ្ធនាការប្រើប្រាស់ប្រព័ន្ធឃោសនាពហុស្ថានីយ៍ដោយមានសារ ស្តីពីបញ្ហាសុខភាពរបស់ស្ត្រី ការបង្ការការចម្លងមេរោគអេដស៍ ការថែទាំ គាំទ្រ និងសិទ្ធិស្ត្រីក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងការមានផ្ទៃពោះ និង ព័ត៌មានពាក់ព័ន្ធផ្លូវភេទ។ | -ក្រស-គ.ជ.ស<br>-ក្រសួងព័ត៌មាន<br>-រដ្ឋបាលថ្នាក់ក្រោមជាតិ<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| • គាំទ្រ និងតាមដានកម្មវិធីផ្លាស់ប្តូរការប្រព្រឹត្តរបស់បុរស និងក្មេងប្រុស និងជំរុញឱ្យមានសារស្តីពីសមភាព និងការគោរពរវាងបុរស និងស្ត្រី និងការប្រព្រឹត្តរួមភេទប្រកបដោយការទទួលខុសត្រូវ។ | -គ.ជ.ស.ស.ខ<br>-ក្រសួងអប់រំ យុវជន និងកីឡា |
| • ពង្រឹងគុណភាព និងប្រសិទ្ធភាពការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារីនៅតាមគ្រឹះស្ថានសិក្សា។ | -ក្រសួងអប់រំ យុវជន និងកីឡា |
| • គាំទ្រការលើកកម្ពស់ឱ្យមានការសិក្សាស្រាវជ្រាវស្តីពីភាពងាយរងគ្រោះ ដាក់លាក់ផ្អែកលើយេនឌ័រដែលប្រឈមមុខខ្ពស់នឹងការចម្លងមេរោគ អេដស៍ (អ្នកបំរើការងារនៅក្នុងក្លឹបកំសាន្ត នារីរកស៊ីផ្លូវភេទតាមដងផ្លូវ និងក្រុមអ្នកស្រលាញ់ភេទដូចគ្នា ស្ត្រីដែលចាក់គ្រឿងញៀន ស្ត្រីដែលជាប់ពន្ធនាគារ និងមជ្ឈមណ្ឌលកែប្រែ) រួមទាំងសក្តានុពលទំនាក់ទំនងរបស់ពួកគេ និងតម្រូវការយេនឌ័រជាក់លាក់។ | -ក្រសួងកិច្ចការនារី<br>-ក្រសួងសុខាភិបាល<br>-អង្គការសង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍<br>-ក្រសួងទេសចរណ៍<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងយុត្តិធម៌<br>-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |

| | |
|---|---|
| **៥. ពង្រឹង និងពង្រីកកម្មវិធីធ្វើការកែប្រែផ្នត់គំនិត និងអាកប្បកិរិយារបស់សង្គម ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី** | |
| • បង្កើតយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយសំដៅកែប្រែ ឬលុបបំបាត់អាកប្បកិរិយា និងផ្នត់គំនិតដែលរើសអើងស្ត្រី រួមមានអាកប្បកិរិយា និងផ្នត់គំនិតដែលមានចែងក្នុង «ច្បាប់ស្រី[41]»។ យោងតាមផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ទី២ គួរមានការបង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយសម្រាប់ជាយុទ្ធសាស្ត្រចម្រុះវិស័យ ដោយផ្តោតលើការកែប្រែគោលគំនិត និងអាកប្បកិរិយាក្នុងចំណោមស្ត្រី។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងស្ថាប័នពាក់ព័ន្ធ<br>-សង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍ |
| **៦. រៀបចំកម្មវិធី និងគោលនយោបាយជាតិ ក្នុងគោលដៅដើម្បីបង្កើនការចូលរួមរបស់ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេចឱ្យកាន់តែច្រើនឡើង** | |
| • បង្កើតគោលនយោបាយ ស្តីពីសមភាពយេនឌ័រដ៏ទូលំទូលាយមួយសម្រាប់គ្រប់គ្រងសមភាពយេនឌ័រ ដែលរួមបញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រីដោយផ្ទាល់ និងដោយប្រយោល[42] ។ គោលនយោបាយនេះ នឹងបញ្ចូលវិធានការវិជ្ជមាន ជាពិសេសការអនុវត្តន៍ចំណុចដៅក្នុងការបង្កើនតំណាងរបស់ស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេចឱ្យបានជាក់លាក់[43]។ | -គ.ជ.ស.ស.ខ<br>-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី<br>-ក្រសួងកិច្ចការនារី<br>ទីស្តីការគណៈរដ្ឋមន្ត្រី |
| • បង្កើន និងគាំទ្រក្រុមស្ត្រី ក្នុងអង្គនីតិប្បញ្ញត្តិ ដើម្បីធ្វើការជាមួយគណបក្សនយោបាយក្នុងការផ្លាស់ប្តូរឱ្យមានឥរិយាបថវិជ្ជមាន។ ប្រការនេះនឹងជំរុញឱ្យតំណាងស្ត្រីទទួលបានការជឿជាក់បន្ថែមទៀត ដើម្បីឱ្យមានការយកចិត្តទុកដាក់លើការបញ្ចេញមតិយោបល់របស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ | -គ.ជ.ស.ស.ខ<br>-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី<br>-រដ្ឋសភា និងព្រឹទ្ធសភា<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

[41] CEDAW C.19a.

[42] CEDAW 11c.

[43] CEDAW 29.

| | |
|---|---|
| • ប្រព័ន្ធទំនាក់ទំនង ព័ត៌មាន និងបច្ចេកវិទ្យា គួរប្រើប្រាស់ដើម្បីផ្សព្វផ្សាយក្នុងចំណោមសមាជិកក្រុមស្ត្រី ដើម្បីឱ្យព័ត៌មានទាំងនោះផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់អ្នកដឹកនាំជាស្ត្រីនៅថ្នាក់ក្រោមជាតិ ។ | -គ.ជ.ស.ស.ខ<br>-ក្រសួងព័ត៌មាន<br>-សង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍<br>-ក្រសួការងារ<br>-ក្រសួងផែនការ |

## ៧. លើកកម្ពស់ការយកចិត្តទុកដាក់ដល់បញ្ហារបស់ស្ត្រីដែលងាយរងគ្រោះ នៅក្នុងការពិភាក្សាអំពីគោលនយោបាយ

| | |
|---|---|
| • ជំរុញ និងគាំទ្រការសិក្សាស្រាវជ្រាវទិន្នន័យពីបញ្ហាតម្រូវការជាក់លាក់របស់ស្ត្រីដែលស្ថិតក្នុងក្រុមងាយរងគ្រោះជាពិសេសជនពិការ។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងសង្គមកិច្ច អតិតយុទ្ធជន និងយុវនីតិសម្បទា<br>-សង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍ |

## ៨. «លក្ខណៈឯកជន» ជាឧបសគ្គក្នុងការឆ្លើយតបទៅនឹងបញ្ហាសេរីភាពរបស់ស្ត្រីក្នុងបញ្ហាគ្រួសារ

| | |
|---|---|
| • គួរមានការសិក្សាស្រាវជ្រាវពីការលែងលះដោយធ្វើការវិភាគលើផលប៉ះពាល់ដែលកើតចេញពីឥទ្ធិពលយេនឌ័រ និងទំនាក់ទំនងវិសមភាពយេនឌ័រ | -គ.ជ.ស.ស.ខ<br>-ក្រសួងយុត្តិធម៌ |

| | |
|---|---|
| • គួរពិនិត្យ និងពិចារណាលើគោលនយោបាយដែលមានវិសមភាពទំនាក់ទំនងយេនឌ័រ ដែលមិនអាចមើលឃើញ «រវាងបុរស និងស្ត្រី» ទាក់ទងនឹងលទ្ធភាពទទួលបានទ្រព្យសម្បត្តិ ការប្រើប្រាស់ទ្រព្យសម្បត្តិ និងការធ្វើសេចក្តីសម្រេច។ ការយកចិត្តទុកដាក់បន្ថែមគឺត្រូវការជាចាំបាច់លើទិដ្ឋភាពវិជ្ជមាននៃការចែករំលែកការងាររវាងស្ត្រី និងបុរស ដូចជា ការងារផ្ទះដែលមិនមានប្រាក់កម្រៃ និងការមើលថែទាំកូន និងមនុស្សចាស់ជរាជាដើម។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>ក្រសួងមហាផ្ទៃ |
| • គួរសិក្សាស្រាវជ្រាវអំពីអាពាហ៍ពិពាហ៍វ័យក្មេង (ក្រោមអាយុ១៨ឆ្នាំ) ធៀបទៅនឹងអាយុរៀបការស្របច្បាប់ (១៨ឆ្នាំ) និងចាត់វិធានការកម្រិតគោលនយោបាយសមស្របដើម្បីផ្លាស់ប្តូរអាកប្បកិរិយាក្នុងចំណោមឳពុកម្តាយអំពីសារៈសំខាន់នៃការអប់រំ និងសិទ្ធិស្របច្បាប់របស់ក្មេងស្រីក្នុងការចរចាពីការរៀបអាពាហ៍ពិពាហ៍។ | -គ.ជ.ស.ស.ខ<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងកិច្ចការនារី |

**៩. ការប្រើប្រាស់ទំនាក់ទំនង ព័ត៌មាន និងបច្ចេកវិទ្យា (ICT) ក្នុងចំណោមស្ត្រីមានការរីកចម្រើនជាលំដាប់ ក៏ប៉ុន្តែបទអន្តរាគមន៍ពីគោលនយោបាយនៅមានកម្រិត ដើម្បីធ្វើឱ្យមានការកែប្រែអាកប្បកិរិយា និងសង្គមប្រកបដោយប្រសិទ្ធភាព**

| | |
|---|---|
| • បង្កើត និងកែសម្រួលគោលនយោបាយទូរគមនាគមន៍ ព័ត៌មាន និងបច្ចេកវិទ្យាទូលំទូលាយ ដោយផ្តោតលើការលុបបំបាត់ផ្នត់គំនិតសង្គម ដើម្បីផ្តល់ភាពអង់អាច និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេច។ | -ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ |

| | |
|---|---|
| • ទាក់ទាញឱ្យមានការចូលរួមពីវិស័យឯកជន និងបណ្តាញផ្សព្វផ្សាយសង្គមក្នុងការបង្កើត និងអនុវត្តគោលនយោបាយតាមវិស័យដើម្បីជំរុញតួនាទីគំរូវិជ្ជមានរបស់ស្ត្រីក្នុងវិស័យនយោបាយ និងអាជីវកម្មតាមរយៈការកែប្រែគំនិត និងអាកប្បកិរិយាចំពោះស្ត្រីទាក់ទងនឹងសមត្ថភាពរបស់ពួកគេក្នុងការក្លាយជាអ្នកដឹកនាំ។ សម្របសម្រួលឱកាសបង្កើតបណ្តាញជាយុទ្ធសាស្ត្រសម្រាប់អ្នកដឹកនាំជាស្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ការទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ត្រូវធានាថាមានការយកចិត្តទុកដាក់លើមតិយោបល់របស់ស្ត្រី និងឆ្លុះបញ្ចាំងនៅពេលបង្កើតគោលនយោបាយដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម[44] ។ | -គ.ជ.ស.ស.ខ<br>-ក្រសួងព័ត៌មាន<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍<br>-សមាគមន៍សហគ្រិន<br>-ក្រសួងកិច្ចការនារី<br>-ក្រសួងមហាផ្ទៃ<br>ក្រសួងអប់រំ យុវជន និងកីឡា |

**១០. ស្ត្រី និងកុមារី ជាពិសេសក្រុមស្ត្រីដែលងាយរងគ្រោះ (ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីពិការ ស្ត្រីមានបន្ទុកច្រើនក្នុងគ្រួសារ ចាស់ជរា ជនជាតិដើមភាគតិច) ប្រឈមនឹងឧបសគ្គជាច្រើន ប៉ុន្តែការឆ្លើយតបគោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីដើម្បីដោះស្រាយនិងឆ្លើយតបបញ្ហាទាំងនោះនៅមានកម្រិត**

| | |
|---|---|
| • ជំរុញក្រុមស្ត្រីដែលងាយរងគ្រោះឱ្យទទួលបានព័ត៌មាន ចំណេះដឹង ជំនាញ បច្ចេកទេស ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។<br>• លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងដំណើរការរៀបចំផែនការដែលឆ្លើយតបនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍឃុំសង្កាត់ ។ | -គ.ជ.ស.ស.ខ<br>-ក្រសួងស្ថាប័នដែលជាសមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |

[44] CEDAW 19c.

| | |
|---|---|
| • បង្កើនកាលានុវត្តភាពការចូលរួមរបស់ស្ត្រីក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយគ្រោះមហន្តរាយតាមរយៈ ការជំរុញ លើកទឹកចិត្ត និងការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នានាទាំងនៅថ្នាក់ជាតិនិងថ្នាក់ ក្រោមជាតិ។ | -ក្រុមការងារបញ្ជ្រាបយេនឌ័រ តាមក្រសួងស្ថាប័នពាក់ព័ន្ធ |
| • សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ជាពិសេស ក្រសួងបរិស្ថាន ដើម្បីដាក់បញ្ចូលបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រគោលនយោបាយ និងកម្មវិធីនានាដើម្បីធានាថាការយកចិត្តទុកដាក់លើការដោះស្រាយ និងឆ្លើយតបតម្រូវការរបស់ក្រុមជនងាយរងគ្រោះ ជាពិសេស ស្ត្រី កុមារ ជនពិការ និងជនជាតិភាគតិច លើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ។ | -សង្គមស៊ីវិល<br>-ដៃគូអភិវឌ្ឍន៍<br>-ក្រសួងបរិស្ថាន |
| • សហការអនុវត្តកម្មវិធីសាកល្បងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដៃគូ អភិវឌ្ឍន៍ សង្គមស៊ីវិល ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ស្ត្រី។ | -ក្រសួងកិច្ចការនារី |
| • ចាត់វិធានការវិជ្ជមានដើម្បីជំរុញស្ត្រីរស់នៅតំបន់ជនបទឱ្យទទួលបានការអប់រំទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និងដើរតួនាទីសំខាន់ក្នុងការធ្វើសេចក្តីសម្រេច[45] ។ | -ក្រសួងអភិវឌ្ឍជនបទ<br>-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>-ក្រសួងកិច្ចការនារី<br>-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |

[45] CEDAW 41c.

| | |
|---|---|
| • ពិនិត្យ និងឆ្លុះបញ្ចាំងឥទ្ធិពលនៃទំនាក់ទំនងយេនឌ័រ ដែលដាក់គំនៀបលើស្ត្រីរស់នៅតំបន់ជនបទដើម្បីបង្កើតគោលនយោបាយក្នុងវិស័យអភិវឌ្ឍជនបទ និងកសិកម្ម។ បញ្ចូលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានសម្រាប់កម្មវិធីផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីរស់នៅតំបន់ជនបទ[46] ។ | -ក្រសួងអភិវឌ្ឍជនបទ<br>ក្រសួងអប់រំ យុវជន និងកីឡា |
| • ពង្រឹងគុណភាពអប់រំប្រកបដោយសមភាពនិងសមធម៌ទៅដល់គ្រប់សាលារៀននៅតាមជនបទ និងតំបន់ដាច់ស្រយាល និងលើកកម្ពស់ការចូលរួមរបស់ជនជាតិដើមភាគតិចឱ្យបញ្ជូនកូនស្រីមករៀន។ បង្កលក្ខណៈ និងផ្តល់លទ្ធភាពឱ្យស្ត្រី និងកុមារីមក ពីគ្រួសារក្រីក្រ និងជនជាតិដើមភាគតិចទទួលបានការអប់រំចំណេះទូទៅពេញលេញ អក្ខរកម្មនិងបំណិនជីវិតគ្រប់គ្រាន់។ | -គ.ជ.ស.ស.ខ<br>-ក្រសួងកិច្ចការនារី<br>-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី<br>-ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងអភិវឌ្ឍន៍ជនបទ<br>ក្រសួងព័ត៌មាន<br>-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ក្រសួងកសិកម្ម<br>-ក្រសួងការងារ |

[46] CEDAW 41a.

# សេចក្ដីថ្លែងអំណរគុណ

ការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាត្រូវបានចងក្រងឡើងនៅក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងកិច្ចការនារី ដោយមានការគាំទ្រនិងរួមចំណែកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល។ ក្រសួងកិច្ចការនារីសូមថ្លែងអំណរគុណ ជូនចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមចំណែកក្នុងការរៀបចំ ឯកសារនេះ ដូចតទៅ៖

**ក្រុមការងាររៀបចំការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជា** ទទួលខុសត្រូវលើដំណើរការ រៀបចំឯកសារទាំងមូល ក្រោមការដឹកនាំរបស់ លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្រុមការងារមានលោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ ជាប្រធាន និងគាំទ្របច្ចេកទេសដោយផ្ទាល់ពីលោកជំទាវ កេត សំអាត ទីប្រឹក្សាជាន់ខ្ពស់ ក្រសួងកិច្ចការនារី លោកជំទាវ គឹម ស៊ីផាត់ អគ្គនាយិកា ក្រសួងកិច្ចការនារី និង លោក ថៃ ឈុនហាក់អគ្គនាយករងក្រសួងកិច្ចការនារីលោកស្រី ញាណ សុចិត្រា ប្រធាននាយកដ្ឋាន សមភាពយេនឌ័រ លោកស្រី តែ វួចលីម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ និងសមាជិក ផ្សេងៗទៀតមកពីនាយកដ្ឋានបច្ចេកទេសនានាចំណុះក្រសួងកិច្ចការនារី។ ក្រុមការងារមាន ការគាំទ្រផ្នែកបច្ចេកទេសពីគម្រោង **ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ** (PGEIII) ដែលមាន លោកស្រី Mia Hyun ជាទីប្រឹក្សាជាន់ខ្ពស់ប្រចាំក្រសួងកិច្ចការនារី ជាអ្នកសម្របសម្រួល ទូទៅ គាំទ្រដោយក្រុមអ្នកជំនាញតាមវិស័យរបស់គម្រោង រួមមាន លោកស្រី ឌី ម៉ានី លោក ប៉ែន បូរី លោកស្រី ហេង សិលទិ លោក ឈន ថាវរិទ្ធិ និង លោក គឹម សុពណ៌។ **ក្រុមការងារបច្ចេកទេសយេនឌ័រ** (TWG-G) បានផ្ដល់ជាវេទិកាដ៏សំខាន់ក្នុងការពិគ្រោះ យោបល់ជាមួយអ្នកពាក់ព័ន្ធ និងក្រុមអ្នកជួយកែសម្រួល (peer reviewers) ដែលជាអ្នក ជំនាញមកពីក្រសួងកិច្ចការនារី ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល បានជួយ ពិនិត្យ ឡើងវិញលើសេចក្ដីព្រាងតាមជំនាញពាក់ព័ន្ធ។ បច្ចេកទេសទាក់ទងនឹងរូបភាព ការរចនា និងសម្ភារៈសម្រាប់ផ្សព្វផ្សាយផ្ដល់ដោយ Good Morning Beautiful ។

**ក្រុមអ្នកដឹកនាំនិងរៀបចំជំពូកទី១៖** ជំពូកនេះដឹកនាំរៀបចំដោយលោកជំទាវ ហ៊ូ សាមិត្ត និងចងក្រងសេចក្ដីព្រាងដោយលោកស្រី Kasumi Nakagawa ក្រោមការ ឧបត្ថម្ភរបស់ UNDP/PGE ដោយមានការផ្ដល់ធាតុចូលពីនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធ របស់ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រសួងអប់រំ យុវជន និងកីឡា។ ជំនួយបច្ចេកទេសទូទៅផ្ដល់ដោយលោក គឹម សុពណ៌ ។

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh
ហ្វេសប៊ុក : www.facebook.com/mowa.gov.kh